# ទស្សនាវដ្តីកម្ពុជសុរិយា

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

លេខ ៧
ឆ្នាំ [illegible]
ព.ស. ២៤៩៩
គ.ស. ១៩៥៥



ពិធីដង្ហែព្រះសារីរិកធាតុទៅក្រុងបេក

អក្សរ សៅ.ចេស · គំនូរ-ឡុង · ជាំង.ស៊ីណរ៉ុង

- R: Tossāneavaddey Mittsalabaley" R. 6 22-12-55




ក្នុងសេចក្ដីថ្លែងសុន្ទរកថារបស់លោក ប៉េ - យ៉ាន ដែលបានថ្លែងក្នុងឱកាសពិធីបុណ្យប្រគល់ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ជូនមករាជរដ្ឋាភិបាលកាលពីថ្ងៃទី ២៥ មិថុនា ១៩៥៥នេះ, លោក ប៉េ-យ៉ាន បានបញ្ជាក់ថា មូលហេតុដែលនាំឲ្យលោកហ៊ានបរិច្ចាគទ្រព្យ (ដែលតាមស្មានប្រហែល ៧០០.០០០ រៀល នោះ)

១- លោកគិតជាយូរមកហើយថា បំណាច់កើតមកបានជាន់បានឃើញព្រះពុទ្ធសាសនា ត្រូវកសាងគ្រឹះស្ថានអ្វីមួយដែលមានប្រយោជន៍ដល់ព្រះពុទ្ធសាសនាទុកជាអនុស្សាវរីយ៍នៃទឹកចិត្តដែលរាប់អានព្រះពុទ្ធនិងកំឡាំងសមត្ថភាពរបស់ខ្លួន ។

២- លោកថាជួនជាកំពូលប្រសើរវិសេសណាស់ ដែលឱកាសមួយនោះទទួល ព្រះពោធិវង្សចាន់ហ្វាន សាលាបាលីក្រោយដែលបាននិមន្តទៅមើលការសិក្សាឯនានាប្រទេសនឹងបានធ្វើសេចក្ដីរាយការណ៍ ថ្វាយព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង (នរោត្តមសីហនុ) រួច, ព្រះមហាក្សត្រិយ៍ទ្រង់បានត្រាស់បញ្ជាឲ្យក្រសួងធម្មការចាត់ការកសាងមហាវិទ្យាល័យឡើង ។

៣- លោកប៉េ-យ៉ានថា ជាកំពូលសំណាងយ៉ាងវិសេសទៅទៀត គឺពេលដែលព្រះមហាក្សត្រិយ៍ត្រាស់បញ្ជាមក, ទទួលថាការជាតិពុំសូវបរិបូណ៌ ម្ល៉ោះហើយ. លោកក៏បានឱកាសនោះចំណាយប្រាក់ផ្ទាល់ខ្លួនកសាងឡើងតែម្ដង ។

ចំពោះសេចក្ដីបញ្ជាក់ដូចខាងលើនេះ យើងឃើញថាលោកប៉េ-យ៉ាន ដែលបានគិតនឹងចំណាយធនធានទុកជាមូលនិធិក្នុងព្រះពុទ្ធសាសនា បានសំរេចដូចបំណងលោកគ្រប់យ៉ាង ហើយត្រឹមត្រូវតាមកាលៈទេសៈផង ។

ក្នុងការកសាងនេះបើនិយាយពីបុណ្យ, យើង

មិនបាច់ពោលដល់រូបវត្ថុដែលធ្វើពីបេតុងការមេ៉ ថាជាប់យូរឬជាប់បានប៉ុណ្ណោះឆ្នាំប៉ុណ្ណោះឆ្នាំនោះទេ, ព្រោះមូលនិធិរបស់លោកបេ-យានេះ ជាវត្ថុមួយដ៏ជិតជាប់នឹងព្រលឹងវិញ្ញាណលោក ដោយពុំមានបាក់បែកទៅណាសោះឡើយ ។ ត្រង់ណេះព្រះសម្ពុទ្ធបរមគ្រូក៏ទ្រង់ត្រាស់ថា ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ អបហាយ គមនេយ្យេសុ ឯតំ អាទាយ គច្ឆតិ បានសេចក្ដីជាខេមរភាសាថា: មូលនិធិនេះដែលគេដឹកល់ទុកល្អហើយរមែងមិនលះបង់ចោលគេទេ គឺជាប់តាមខ្លួនគេក្នុងកាលតៗគ្នាទៅ ហើយធ្វើឲ្យគេមិនចាលចាញ់ ក្នុងកពណាៗទាំងអស់, មូលនិធិនេះនរណាក៏លួចយករបស់គេពុំបានដែរ ។

យើងយល់ថាលោកបេ-យាន មានភ័ព្វសំណាងល្អណាស់ គឺលោកកើតមកហើយលោកបានជាអ្នកមានទ្រព្យ រួចលោកបានជាមនុស្សសម្មាទិដ្ឋិ មិនតែប៉ុណ្ណោះ លោកបានទុកកេរ្តិ៍ឈ្មោះ ជាប់នៅក្នុងដួងហឫទ័យនៃពុទ្ធមាមកជនទូទៅទៀតផង ។ កម្រកមនុស្សណ.ណ កើតមកមានភ័ព្វដូចលោកបេ-យានបាន ។

មានការគួរស្ងើចជាពិសេស គឺលោកបេ-យានេះ កាលមានគេសួរថា លោកធ្វើបុណ្យអស់ប្រហែលប៉ុន្មាន លោកគាំងចិត្តថានឹងធ្វើឲ្យអស់ប៉ុន្មានទៅទៀត ? លោកតបថា ខ្ញុំពុំដឹងជាអស់ប៉ុន្មាន ហើយមិនគាំងចិត្តថាឲ្យអស់ប៉ុណ្ណះប៉ុណ្ណោះសោះឡើយ, គឺថាអស់ប៉ុន្មានក៏អស់ទៅឲ្យតែសំរេចនូវអ្វីមួយ ដែលយើងគាំងចិត្តនឹងធ្វើប៉ុណ្ណោះ ។

ចំពោះប្រសាសន៍នេះ គឺថាលោកគហបតីនេះមិនញាប់ញ័រ ឬភ័យខ្លាចពីរឿងចំណាយធ្វើទានសោះឡើយ គួរចាត់ជាអចលសទ្ធាដោយពិត ។

អ្នកផងដឹងច្បាស់ថាគហបតីបេ-យានពុំមែនគាត់និយាយអួតអាងទេ គឺពិតជាដូចពាក្យថាជាប្រាកដណាស់ គួរជ្រាបថាអំពើដែលធ្វើ គួរជាទីអស្ចារ្យមែនមួយទៀតរបស់លោកបេ-យានេះ បើយើងសំដែងឲ្យឃើញនូវទិដ្ឋធម្មវេទនីយ គឺកុសលជួយយ៉ាងទាន់ហន់វិញ យើងអាចលើកយកបង្ហាញបានដែរ ដូចកាលពួកចោរកំណាចដែលមានកលល្បិចយ៉ាងសម្បើមចាប់គាត់ទាំងថ្ងៃ នៅកណ្ដាលក្រុងភ្នំពេញនោះ, ពេលនោះគឺគាត់អស់សង្ឃឹមក្នុងជីវិត, ក្នុងទ្រព្យសម្បត្តិរលីងលេងទៅ ហើយនៅសល់តែចិត្តបរិសុទ្ធដែលគាត់ប្រវត្តិចំពោះកុសលកសាងប៉ុណ្ណោះ ។ ដោយអំណាចកុសលផលបុណ្យនោះឯងក៏បានជួយឲ្យគាត់ផុតពីគ្រោះទាំងពីរ ដោយគ្មានទទួលទុក្ខអ្វីសោះ ។

គាត់សប្បាយនឹងបុណ្យ ហើយបុណ្យជួយគាត់ដូចមានរឿងនិទានក្នុងគម្ពីរព្រះពុទ្ធសាសនាពិតមែន ។ ដូច្នេះ តើនរណាស្អប់បុណ្យ តើនរណាខ្ពើមបុណ្យកើត, ពួកពាលទេដែលពិចារណារឿងបុណ្យមិនច្បាស់លាស់ គេស្អាក់ស្មើរនឹងធ្វើបុណ្យ ថែមទាំងខ្វល់បណ្ដុះចិត្តឲ្យទៅជាបុណ្យផង ។

អច្ឆរិយគាថា

# ពោលអំពីហេតុជាទីអស្ចារ្យ



១- សេចក្តីអស្ចារ្យក្នុងលោកមានច្រើនយ៉ាង!...

២- សេចក្តីអស្ចារ្យនៃខុប្បាទិន្នកសង្ខារក៏មាន!...

៣- សេចក្តីអស្ចារ្យនៃអនុប្បាទិន្នកសង្ខារក៏មាន!...

ចុះធម៌វិន័យមានសេចក្តីអស្ចារ្យយ៉ាងណាខ្លះ? បើប្រៀបធៀបដោយអនុប្បាទិន្នកសង្ខារមួយបានឬទេ?

មហាសមុទ្រមានធម្មតាអស្ចារ្យចម្លែក ៨ យ៉ាងគឺ

១. មហាសមុទ្រ មានទីទំនាប ទីជម្រាល ទីទេរទៅ ដោយលំដាប់មិនមែនចោតជ្រៅទៅតែម្តងជាអណ្តូងទេ ។

២- មហាសមុទ្រមានទឹកដក់នៅនឹងធម្មតាមិនដែលឡើង ឬ ជោរហួសមាត់ច្រាំងឡើយ ។

៣- មហាសមុទ្រ មិនដែលមានសាកសពនៅរួមបាន បើមានសាកសពស្លាប់ក្នុងមហាសមុទ្រ រលកតែងបន្ទក់ទៅរកមាត់ច្រាំងហើយផាត់ឡើងទៅលើគោកមួយរំពេច ។

៤- ទន្លេធំតាំងឡាយឯណានីមួយ ដូចជាទន្លេគង្គា, យមុនា, អចិរវតី សរភូ, មហី ទន្លេទាំងនេះ កាលបើហូរទៅដល់មហាសមុទ្រហើយ រមែងលះបង់នាមនិងគោត្តដើមរបស់ខ្លួនរួបបញ្ចូលថា មហាសមុទ្រតែម្យ៉ាង ។

៥- ទឹកទន្លេទាំងឡាយឯណានីមួយក្នុងលោកដែលហូរចុះទៅរកមហាសមុទ្រក្តី ទឹកភ្លៀងឯណាដែលហូរស្រោចចុះមកពីលើអាកាសក្តី មហាសមុទ្រក៏មិនដែលប្រាកដជាស្រកឬពេញដោយទឹក នឹងទឹកភ្លៀងនោះឡើយ ។

៦- មហាសមុទ្រ មានរសតែមួយ គឺរសប្រៃ ។

៧- មហាសមុទ្រមានរតនវត្ថុ (ទ្រព្យជាគ្រឿងពេញចិត្ត) ច្រើនយ៉ាងគឺ កែវមុក្តា, កែវមណី, កែវពិទូរ្យ

សង្ខ, សិលា, កែវប្រពាឡ, ប្រាក់, មាស, កែវក្រហម (ត្បូងទទឹម) និងកែវមរកត ។

៨- មហាសមុទ្រ ជាទីនៅអាស្រ័យនៃសត្វធំៗ ជាច្រើន គឺត្រីឈ្មោះ តិមិ, តិមិង្គល, មហាតិមិង្គលនិង ពួកអសុរ, នាគ, គន្ធព្វ,តែងនៅក្នុងមហាសមុទ្រនោះ ។ វិនយបិដក ចុល្លវគ្គ តតិយភាគ ទី ១១ ទំព័រ ២០៤ ។

ឯធម្មវិន័យក៏មានធម្មតាអស្ចារ្យ ៨ ប្រការដែរ

១- ក្នុងធម្មវិន័យនេះ មានការសិក្សា មានកិច្ច ដែលត្រូវធ្វើ មានសេចក្តីប្រតិបត្តិដោយលំដាប់មិនមែន ស្រាប់តែបានត្រាស់ដឹងព្រះអរហត្តផលតែម្តងទេ ដូចជាមហាសមុទ្រ ដែលមានទីទំនាបដោយលំដាប់ដូច្នោះ ឯង ។

២- សិក្ខាបទឯណា ដែលព្រះតថាគតបាន សំដែងហើយ បានបញ្ញត្តហើយដល់សាវក ពួកសាវក នៃព្រះតថាគត សូម្បីមានហេតុដល់ដល់ជីវិត ក៏មិន ហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ ដូចមហាសមុទ្រ ដែលមិនឡើង ឬជោរហួសច្រាំងទៅបានដូច្នោះឯង ។

៣- បុគ្គលណា ជាអ្នកទ្រុស្តសីល មានធម៌ អាក្រក់មានមារយាទមិនល្អ គួរឲ្យគេរង្កៀស មានអំពើ អាក្រក់បិទបាំងទុក មិនមែនជាសមណៈនោះ តែប្តេជ្ញា ខ្លួនថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុងមានចិត្តទទឹកជោរជោកដោយរាគៈ ក្រខ្វក់ដូច សំរាម សង្ឃនៅរួមជាមួយបុគ្គលនោះមិនបាន សង្ឃក៏ ប្រជុំគ្នានឹងយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ ទោះបីអង្គុយនៅពាក់កណ្តាលភិក្ខុសង្ឃ ក៏ឈ្មោះថានៅ ឆ្ងាយអំពីសង្ឃដោយពិត ចំណែកខាងសង្ឃវិញសោត ក៏ឈ្មោះថានៅឆ្ងាយអំពីបុគ្គលនោះ ដូចជាមហាសមុទ្រ មិនមានសាកសពនៅរួមបានដូច្នោះឯង ។

៤- វណ្ណៈទាំង ៤ គឺ ខត្តិយៈ, ព្រាហ្មណៈ វេស្សៈ, សុទ្ទៈ ចេញចាកគេហស្ថាន មកបួសក្នុងធម្ម វិន័យដែលតថាគតបានសំដែងហើយ រមែងលះបង់ នាមនិងគោត្តដើមរបស់ខ្លួន រាប់បញ្ចូលថាជា សមណៈ- បុត្រតែម្យ៉ាងដូចទន្លេធំៗ ដែលហូរទៅដល់មហាសមុទ្រ តែងតែលះបង់នាមនិងគោត្តរបស់ខ្លួនដូច្នោះឯង ។

៥- ទោះបីពួកភិក្ខុច្រើនរូបបរិនិព្វានដោយ អនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដថាខ្វះ ឬពេញដោយភិក្ខុទាំងនោះឡើយ ដូចជាទឹកទន្លេដែល ហូរចុះទៅរកមហាសមុទ្រក្តី ទាំងទឹកភ្លៀងដែលហូរ ស្រោចចុះមកពីផ្ទៃអាកាសក្តី មហាសមុទ្រក៏មិនប្រាកដ ជាស្រកឬពេញដោយទឹកដូច្នោះឯង ។

៦- ធម្មវិន័យមានឧជារសតែមួយគឺវិមុត្តិរស ដូច ជាមហាសមុទ្រ ដែលមានឧជារសតែមួយគឺលោណៈ- រស រសប្រៃដូច្នោះឯង ។

៧- ធម្មវិន័យមាន(ធម្មជាទីរីករាយ)ច្រើនយ៉ាងគឺ សតិបដ្ឋាន៤, សម្មប្បធាន ៤, ឥទ្ធិបាទ៤, ឥន្ទ្រិយ៥, ពល៥, ពោជ្ឈង្គ៧, អដ្ឋង្គិកមគ្គ៨ ដែលជាផ្លូវដ៏បវរ ដូចជាមហាសមុទ្រមានរតនៈច្រើនយ៉ាង មានកែវមុក្តា ជាដើមដូច្នោះឯង ។

៨- ធម៌វិន័យជាទីនៅអាស្រ័យនៃបុគ្គលធំៗ ជាច្រើន គឺសោតាបន្នបុគ្គល និងបុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលជាដើម មានព្រះអរហន្តនិងបុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផលជាបរិយោសាន ដូចមហាសមុទ្រដែលជាទីអាស្រ័យនៅនៃពួកសត្វធំៗ មានត្រីឈ្មោះតិមិជាដើម ដូច្នោះឯង ។

វិន័យបិដក ចុល្លវគ្គ តតិយភាគទី១១ ទំព័រ២០៩ ។

ព្រះគ្រូសាសនវង្ស

ប៉ាង-ខិត

x x

x

## ដំរីខ្វាក់ទ្រមាក់ធ្លុត

ពាក្យ២បទនេះ ជាសុភាសិតខ្មែរបុរាណ លោកនិយាយប្រៀបធៀប ទុកប្រដៅកូនចៅខាងក្រោយឲ្យដឹងសេចក្ដីថាធម្មតាសត្វបំរើដូចជាគោ, ក្របី, សេះ, ដំរីជាដើមវាតែងស្ដាប់បង្គាប់ម្ចាស់ ឲ្យសញ្ញាវាដូចម្ដេចវាក៏ធ្វើតាមដូច្នោះ ប្រែថាសត្វពាហនៈទាំងអស់ទទួលធ្វើការឲ្យម្ចាស់តាមកំឡាំងកាយរបស់វាប៉ុណ្ណោះ វាឥតគំនិតប្រាជ្ញាជួយគិតគូម្ចាស់ទេ ឯការខុសត្រូវចំរើនឬខូចខាតស្រេចលើម្ចាស់ បើម្ចាស់គិតត្រូវហើយចេះប្រើវាក៏បានសម្រេចផលប្រយោជន៍ បើម្ចាស់គិតខុសឬក៏មិនចេះប្រើវា ក៏ខូចខាតផលប្រយោជន៍ រួមសេចក្ដីឲ្យខ្លីថា "កំឡាំងនៅលើសត្វបំរើ គំនិតនៅលើម្ចាស់អ្នកប្រើ" ចុះបើសត្វបំរើនោះខ្វាក់ហើយ ថែមទាំងម្ចាស់នោះធ្លុតទៀត តើនឹងបានសម្រេចផលប្រយោជន៍ដែរឬទេ ?

សុភាសិតខាងលើនេះ ត្រង់បទថា "ដំរីខ្វាក់" លោកប្រៀបដូចកូនសិស្ស ដែលកំពុងតែរៀនសូត្រ មិនទាន់ចេះដឹងមិនទាន់យល់ការខុសត្រូវនឹង ប្រៀបដូចអ្នកទទួលធ្វើការបំរើគេ ។ ត្រង់បទថា "ទ្រមាក់ធ្លុត" លោកប្រៀបដូចគ្រូអាចារ្យដែលបង្រៀនសិស្សខុស និងប្រៀបដូចអ្នកជាអាណាព្យាបាលបង្គាប់បញ្ជាគេខុស ដោយហេតុគំនិតខ្លួនភាន់ច្រឡំ ដោយហេតុខ្លួនមិនចេះមិនដឹងក្ដី ។ ធម្មតាមនុស្សធ្លុតហើយ កុំថាប្រើដំរីខ្វាក់ សូម្បីដំរីមិនខ្វាក់ ក៏នៅតែប្រើវាមិនកើតដែរ ព្រោះខ្លួនខូចសតិស្មារតីអស់ហើយ ។

ហេតុនេះ លោក-អ្នកជាគ្រូអាចារ្យឬជាអាណា-ព្យាបាល ត្រូវបង្រៀនសិស្ស ឬប្រើគេ តាមសេចក្ដីចេះដឹងរបស់ខ្លួនពិតៗកុំស្មានថា បើខ្លួនក្លែងក្លាំងឬមិនចេះ ត្រូវប្រាប់គេឲ្យត្រង់កុំបន្លំ ហើយត្រូវខំស្វែងរកក្បួនខ្នាតមើល ឬសាកសួរលោកអ្នកប្រាជ្ញឲ្យទាល់តែបានចេះដឹងរឿងនោះៗឡើង ធ្វើយ៉ាងនេះទើបនឹងកើតមានសេចក្ដីចំរើនដល់ខ្លួនផង ដល់សិស្សនិងអ្នកទទួលបង្គាប់ផងដើម្បីនឹងចៀសវាងពាក្យ គេតិះដៀលថា "ដំរីខ្វាក់ទ្រមាក់ធ្លុត" ផង ។

## និទានរឿងគ្រូនិងសិស្ស

កាលពី គ.ស.១៩២១ ខ្ញុំ[១]បួសនេននៅវត្តបទុម

១) ឈ្មោះ ប៉ូ-ប៉ូ អ្នកសរសេររឿងនេះ ។

វត្ត ក្រុងគ្នាពេញបាន៣វស្សា លោកគ្រូប្រើខ្ញុំឲ្យបង្រៀនអក្សរក្មេងៗច្រើននាក់ៗ មានក្មេងម្នាក់រៀនមើលសាស្ត្រាបឋមសម្ពោធិ ដល់ទៅត្រង់រឿងថា "កាលព្រះពុទ្ធអង្គយាងចូលបង្គន់ ក៏មានលាមកសុទ្ធតែឈាម មានក្មេងម្នាក់ទៀតនៅជិតគ្នាហើយនឹកឆ្ងល់សួរខ្ញុំថា "ទាន! ចុះអ្នកណា លាគេមកពីណា" ៗ ខ្ញុំឆ្លើយថា "ម៉េចក៏ឯងមិនដឹង! កាលព្រះចូលបង្គន់នោះ មានបុរសម្នាក់តាមទៅរកព្រះ លុះឃើញឈាមប្រឡាក់បង្គន់ គេក៏លាព្រះចេញមកវិញ ប៉ុន្តែគេនិយាយគាត់ឲ្យខ្ញុំថា "លាមក សុទ្ធតែឈាម"ៗ ការជំលែកគ្នាពីរឿងនេះកាន់តែតឹងសំឡេងដោយខ្លាំងឡើងក៏ឮដល់លោកគ្រូ សាកសួរជ្រាបហើយបន្ទោសថា "នេនឯងប្រាប់ក្មេងខុសហើយ មិនមែនដូចនេនឯងយល់នោះទេ ហេតុហ្នឹងបានចាស់ទុំលោកថា "ដើរទ្វាក់ក្រុមមាក់ឆ្អត" ៗ

ខ្ញុំទើបចូលសួរលោកគ្រូវិញថា "ទានប្រោស! ចុះសេចក្តីនោះដូចម្តេចទៅវិញ? ៗ

លោកគ្រូ— កាលព្រះចូលបង្គន់ ព្រះអង្គជុះអាចម៍មកសុទ្ធតែឈាម ប៉ុន្តែពាក្យខ្ពស់គេថា លាមក ជំនួស អាចម៍ វិញ, លាមក នេះជាពាក្យបាលី ប្រែថា អាចម៍ ៗ

—ទានប្រោស! ខ្ញុំព្រះករុណាយល់ហើយ ប៉ុន្តែនៅឆ្ងល់ត្រង់តួអក្សរទៀត ម៉េចក៏គេមិនដាក់បន្តក់ថា លាមក់ យ៉ាងនេះវិញ?

—ទេ! ព្រោះពាក្យនេះ ជាភាសាបាលី គេមិនត្រូវដាក់បន្តក់ទេ ៗ

—ទានប្រោស! ស្តាប់បានហើយ ចុះត្រង់ អាចម៍ ម៉េចក៏គេមិនដាក់បន្តក់លើតួ ចដែរ ហើយម៉េចក៏មានតួម មួយទៀត ឲ្យអានថា អាច់ ខុសពីអក្សរដែលសរសេរនោះទៅវិញ?

—នែនេន! ពាក្យនេះ ក៏មកពីភាសាបាលីដែរ ថា អាចៈមៈ ប្រើជាពាក្យខ្ពស់ថា អាចម (អាចំ) ប្រើជាពាក្យទាបថា អាចម៍ (អាច់), ពាក្យថា អាចំ ឬ អាច់ នេះជាភាសាបាលីដូចគ្នា ៗ

—ទានប្រោស! ខ្ញុំព្រះករុណាមិនអាចយល់ថា ពាក្យនេះជាបាលីឬសំស្ក្រឹតឬក៏ជាពាក្យខ្មែរទេ ចុះធ្វើដូចម្តេចនឹងដឹងពាក្យ ទាំង ៣ នេះបាន ទាន?

—បើនេនឯង ចង់ដឹងឲ្យច្បាស់ ត្រូវនេនឯងទៅរកគ្រូរៀនភាសាបាលីនឹងសំស្ក្រឹតឲ្យចេះជាមុនសិន កាលបើចេះបាលីនឹងសំស្ក្រឹតហើយ ក៏នឹងយល់ថាពាក្យនេះជាពាក្យខ្មែរពាក្យនេះជាបាលីឬសំស្ក្រឹត ៗ

នែនេន! សំដីដែលជាតិខ្មែរនិយាយគ្នាឬសរសេរសព្វថ្ងៃនេះ លាយចម្រុះច្រើនភាសាណាស់ លាយបាលី, សំស្ក្រឹត, សៀម, យួន, ចិន, បារាំង ៗ

ខ្ញុំឮលោកគ្រូប្រាប់ដូច្នោះ ក៏ថ្វាយបង្គំលាមកវិញហើយរករៀនភាសាបាលីនឹងសំស្ក្រឹត កន្លង ៥ ឆ្នាំខ្ញុំក៏បានចេះខ្លះទើបដឹងច្បាស់ថា ពាក្យខ្មែរលំបាករៀនណាស់តើ ៗ

ដោយហេតុដូចបានអធិប្បាយមកនេះហើយ បាន

ជាលោកបោរាណាចារ្យខ្មែរចងក្រងជាសុភាសិតទុក ទូន្មានកូនចៅជាន់ក្រោយថា «បើអ្នក-នាងធ្វើជាគ្រូក្ដី ជាអាណាព្យាបាលគេក្ដី ចូរប្រុងប្រយ័ត្នឲ្យណាស់កុំឲ្យខុសខ្លួន កុំឲ្យគេតិះដៀលថា «ដំរីខ្វាក់ទ្រមាក់ធ្លក» ។

បេះពីររៀនមានពីរក

ប៊ី-ប៊ី

x

x

x

## គុណនៃសេចក្ដីព្យាយាម

រីគុណនៃសេចក្ដីព្យាយាម ខ្ញុំបរិយាយតាមពាក្យកវី ជូនដល់អស់លោកទាំងប្រុសស្រី ដូចមានសេចក្ដីតទៅថាៈ

ខំប្រឹងធ្វើស្រែនឹងបានស្រូវ
ខំប្រឹងធ្វើផ្លូវស្រួលយាត្រា
ខំប្រឹងដុសក្អែលស្អាតកាយា
ខំប្រឹងកាត់អារនឹងបានដាច់ ។
ខំប្រឹងដកគាស់នឹងរលំ
ខំប្រឹងចងផ្គុំបានជាបាច់
ខំប្រឹងបរបាញ់នឹងបានសាច់
ខំប្រឹងឲ្យដាច់នឹងលែងជាប់ ។
ខំប្រឹងរក្សាមិនមានបាត់
ខំប្រឹងហ្វឹកហាត់នឹងបានស្ទាប់
ខំប្រឹងចូលគាល់នឹងបានគាប់
ខំប្រឹងថែទ្រព្យមិនខូចខាត ។
ខំប្រឹងដុសលាងនឹងបានជ្រះ
ខំប្រឹងជម្រះនឹងបានស្អាត
ខំប្រឹងប្រយ័ត្នគ្នាប្រមាទ
ខំប្រឹងឧហាតនឹងបានផល ។
ខំជីកកកាយនឹងបានជ្រៅ
ខំប្រឹងដើរទៅនឹងបានដល់
ខំប្រឹងសាកសួរនឹងបាត់ឆ្ងល់
ខំធ្វើកុសលនឹងបានសុខ ។
ខំប្រឹងសង្កេតនឹងយល់ការណ៍
ខំពិចារណាយល់ទៅមុខ
ខំប្រឹងខ្វាយខ្វល់រួចចាកទុក្ខ
ខំប្រឹងលុយលុកឈ្នះឧបសគ្គ ។
ខំប្រឹងសិក្សានឹងបានចេះ
ខំផ្ទុននឹងចេះដោយជាន់ជាក់
ខំប្រឹងធ្វើការបានមាស-ប្រាក់
ខំប្រឹងរាក់ទាក់នឹងបានស្នេហ៍ ។
ខំប្រឹងទទូចតង់តែបាន
ខំប្រឹងរុញច្រាននឹងបានបែរ
ខំប្រឹងរៀបរៀងនឹងហូរហែ
ខំប្រឹងធ្លួនថែនឹងថេរឋិត ។
ខំប្រឹងអុំចែវនឹងដល់ត្រើយ

ខំប្រឹងបង្ហើយនឹងផ្លូវចិត្ត
ខំប្រឹងធ្វើស្នេហ៍នឹងបានស្និទ្ធ
ខំប្រឹងប៉ុនប៉ងនឹងជិតបាន ៗ
ខំប្រឹងធ្វើល្អនឹងបានល្អ
ខំប្រឹងស្មោះសរគេរាប់អាន
ខំប្រឹងធ្វើញយនឹងចំណាន
ខំប្រឹងហាត់អាននឹងរត់មាត់ ៗ
ខំប្រឹងទន្ទេញនឹងបានចាំ
ខំប្រឹងចំណាំមិនមានភ្លាត់
ខំប្រឹងប្ទេម្ទេមិនមានព្រាត់
ខំប្រឹងផ្ទៀងផ្ទាត់នឹងបានត្រង់ ៗ
ខំទប់ស្មារតីមិនមានគ្រោះ
ខំប្រឹងលាកលោះនឹងរួចបង់
ខំប្រឹងលះបោលនឹងបាត់ចង់
ខំប្រឹងតម្រង់មិនវៀចវេរ ៗ
ខំប្រឹងសន្សំនឹងបានច្រើន
ខំប្រឹងក្រវើនមិនចំនេរ
ខំប្រឹងរៀនរួចខ្ញុំគេ
ខំប្រឹងរិះរេមានឧបាយ ៗ

ខំប្រឹងអត់ធន់នឹងមិនថយ
ខំប្រឹងលក់ដូរបានលុយចាយ
ខំប្រឹងលះបោលនឹងនឿយណាយ
ខំប្រឹងកំចាយនឹងបានខាត ៗ
ខំប្រឹងវៀរខុសនឹងបានត្រូវ
ខំប្រឹងថែបូរមិនបាត់ស្ងាត់
ខំប្រឹងបណ្ដែតនឹងរសាត់
ខំប្រឹងបំបាត់នឹងលែងមាន ៗ
ខំប្រឹងតស៊ូនឹងបានឈ្នះ
ខំប្រឹងមានះនឹងអាចហ៊ាន
ខំប្រឹងពពាំងគ្មានបំពាន
ខំប្រឹងធ្វើទាននឹងបានបុណ្យ ៗ
ខំប្រឹងរូតរះនឹងបានឆាប់
ខំប្រឹងតាមច្បាប់មិនមានស្មុន
ខំប្រឹងយិតយោងរួចពីដុន
ខំប្រឹងមានគុណស្មោះហើយអើយ ៗ

តាំ-ហៃ

លេខាធិការសមាគមមិត្តសាលាបាលី

x x

x

## ការបង្ហាត់និស្ស័យខេមរបុត្រក្នុងគ្រួសារ

សេចក្ដីចំរើន របៀបបែបផែនរៀបរយ, សន្តិភាពនិងវឌ្ឍនភាព ប្រទេសណាក៏ដោយសឹងត្រូវការសិទ្ធិនិងសេរីភាព គឺជាករណីយកិច្ចរបស់ពលរដ្ឋមួយរូប ៗ, ខេមរបុត្រ គប្បីស្គាល់ដោយច្បាស់ពិតប្រាកដ ទើបញ៉ាំងប្រទេសឲ្យមានការវិវឌ្ឍន៍ទៅកាន់អារ្យធម៌បាន ៗ មនុស្សម្នាក់, ដើម្បីតាំងខ្លួនឲ្យបានជាពលរដ្ឋពេញលក្ខណៈនោះ, ប៉ែកខាងអាណាចក្រ គប្បីវៀរ

ចាកអំពើយង់ឃ្នង ដែលជាទំនាស់ដល់ច្បាប់, ប្រពៃណី សម្រាប់ប្រទេស; ប៉ែកខាងពុទ្ធសាសនចក្រ គប្បីជៀសចេញអំពីការប្រព្រឹត្តិខុសចាកគន្លងនៃពាក្យប្រៀនប្រដៅ ដែលជាវិន័យនៃព្រះសម្មាសម្ពុទ្ធ ៗ ទាំងអស់នេះឯង សុទ្ធតែជាទំនៀមប្រពៃណីដ៏សំខាន់របស់ប្រទេស ៗ សភាវៈអស់នេះ មិនមែនធ្វើនិស្ស័យរបស់មនុស្ស ដែលលូងមានអាយុច្រើនហួសកម្រិតវ័យ ឲ្យបត់បែរ គឺមិនអាចនឹងបំពត់មនុស្សដែលលូងនោះ ឲ្យស្គាល់សិទ្ធិនិងសេរីភាពជាដើមនោះកើតទេ ព្រោះលុះណាតែបង្ហឹកកុមារ–រី ដែលមានវ័យទន់នៅឡើយជាដើមចម ទើបអ្នកអស់នោះស្គាល់បាន ៗ កុមារ-រី តើយើងត្រូវបង្ហាត់អប់រំនិស្ស័យដូចម្តេច? កុមារ-រីដែលគាំងនៅក្នុងប្រឋមវ័យគប្បីសាបព្រួសហើយដាក់ទឹកដីរជាតិយ៉ាងត្រូវកែសក្តិសិទ្ធិ ពោលគឺត្រូវឲ្យចូលសាលាឲ្យគ្រូបង្ហាត់យកចំណេះវិជ្ជាផ្គាល់ខ្លួន ព្រោះអនាគតវែងឆ្ងាយ ដែលក្មេងតូច ៗ អស់នោះ ត្រូវតែញាត់ទុកនូវចំណេះវិជ្ជាក្នុងដួងកមល និងប្រតិបត្តិរក្សាសីលធម៌រៀងខ្លួន ៗ ឯកិច្ចដែលចូលសាលាហើយគប្បីគ្រង់គ្រាប់ស្តាប់ដំបូន្មានដ៏ពិរោះក្បោះក្បាយរបស់គ្រូបាធ្យាយ ដើម្បីគេចវេះអំពីឈ្មោះថា សិស្សអាក្រក់, មិនចេះច្បាប់, គ្មានសណ្តាប់ធ្នាប់"; ចេញពីសាលា មកនៅក្នុងសង្គមនៃគ្រួសារ គប្បីផ្ទៀងត្រចៀកពិនិត្យផ្ទៀកៗនូវសំដីដ៏ផ្អែមត្រជាក់ ធ្លាក់ដល់ថ្លើមបេះដូង នៃមាតាបិតា ឬ អ្នកតព្វបាលលើ ដែលជះមកលើខ្លួន ៗ បើទុកជាមានពាក្យតិះរោះតិះរ៉េយ ក៏គាត់នៅតែស្រឡាញ់អាសូរពេញហឫទ័យ ៗ

ជំពេញប្រពេញពាក់កណ្តាលមនុស្ស តើត្រូវអប់រំដូចម្តេច? មជ្ឈិមវ័យគឺវ័យពាក់កណ្តាល ដែលមនុស្សយើងដឹងច្បាស់នូវករណីសព្វគ្រប់, វិជ្ជាសាស្ត្រ ដែលបានសិក្សាសន្សំបន្តិចម្តងៗ ដូចជាដំណក់ទឹក ក៏មានគ្រប់គ្រាន់កាលខ្លួននៅជាបឋមវ័យ រួចគប្បីបំពេញមុខការមួយបែបទៀត គឺត្រូវប្រកបអាជីវកម្ម; តែការស្វែងរកអាជីពនេះ ទោះខ្លួនមានយសស័ក្តិធំ-តូចប៉ុណ្ណា ៗ ក្តី ទោះបីធ្វើកសិកម្មឬពាណិជ្ជកម្មក្តី គប្បីបដិបត្តិដោយផ្លូវសុចរិត, យុត្តិធម៌ ត្រឹមត្រូវតាមហេតុ ទើបអារ្យធម៌របស់ប្រទេស នឹងមានគតិលឿនទៅមុខបានដោយសេរី ;ប្រទេសជាតិពិតជាមានទម្រង់លក្ខណៈថាជាអារ្យប្រទេសបរិបូណ៌ ៗ ដំណើរការណ៍ ដូចយ៉ាងការសិក្សាវិជ្ជាសាស្ត្រគប់ប្រភេទ ហើយស្រឡាញ់ពេញក្នុងចិត្ត, ស្គាល់ករណីយកិច្ច និងសិទ្ធិព្រមទាំងស្រឡាញ់ជាតិសាសនា - មហាក្សត្រ ជាជារបស់ខ្លួន, ភ័ក្ត្រដ៏ផូរផង់ញញឹមប្រិមប្រិយនៃប្រទេស រមែងបែរត់ទៅរកវឌ្ឍន-ធម៌ជានិច្ចឥតថយក្រោយ តែបើពលរដ្ឋប្រព្រឹត្តឲ្យផ្ទុយអំពីនេះទៅវិញ តើប្រទេសជាតិមាតុភូមិ ចំរើនបានឡើងកាន់អារ្យធម៌ដែរឬទេ ?

ខេមរបុត្រនឹងសន្សឹមផ្តេកចិត្តនៃវដ្តទៅអនាគត ហេតុនេះ យើងត្រូវធ្វើឫកសុភាពសមរម្យជាពលរដ្ឋថ្មីមែនទែន ហើយគប្បីយល់កិច្ចរបស់យើងឲ្យមធ្យ័ត ។

វិប្បធម៌, សីលធម៌... បើយើងបំពេញឲ្យគ្រប់គ្រាន់, អ្នកប្រាជ្ញក៏ចាត់ឈ្មោះថាជាមនុស្សជួយលើកដំកើងពូជពង្សខេមរជាតិ ឲ្យអណ្ដែតលេចធ្លោមួយបានដែរ ។

ផ្នែកពុទ្ធសាសនចក្រមានគាថាមួយកន្លែង ដែលព្រះសម្មាសម្ពុទ្ធជាមកុដនៃត្រៃភព ទ្រង់ចាត់អ្នកមានគុណដ៏ធ្ងន់ជាងគេ គឺមាតាបិតា ថាជាបុព្វការីយ៉ាងដើម ជាមុនដំបូងបង្អស់ ក្នុងចំណោមបុព្វការីទាំងឡាយ, ដ្បិតភាពនៃសង្គមរបស់គ្រួសារ មាតាបិតានោះឯង តែងជាមគ្គនាយកឬមគ្គុទ្ទេសក៍ គឺជាអ្នកត្រាយផ្លូវទំលុះទំលាយនូវសេចក្ដីសៅហ្មងគ្រប់យ៉ាងដែលកើតមានឡើងដ៏អាក្រក់ឧត្បាតចង្រៃចេញឲ្យបានសន្តិភាពល្អ ដល់បុត្រធីតា ៗ គ្រួសារនីមួយៗ រមែងប្រកបដោយមាតាបិតា, បងប្អូន និងញាតិមិត្ត ។ បណ្ដាអ្នករួមសង្គមទាំងអស់នោះ, មាតាបិតានោះឯង លោកជាឥស្សរៈលើជនទាំងពួង ។ មាតាជាអ្នកបង្កើតកូនប្រុសស្រី ហើយជាអ្នកញុំាងបុត្រទាំងនោះឲ្យត្រេកអររីករាយ តាំងតែពីនៅជាទារក រហូតដល់មានអាយុវ័យរឹងប៉ឹងពេញរូបជាយុវជន ។ បិតាជាអ្នកញុំាងកូនប្រុសស្រីនោះ ឲ្យកើតហើយចិញ្ចឹមបីបាច់រហូតមក ៗ អ្នកទាំងពីរស្ទើរហត់នឿយ, ស្ទើរតែលំបាកក្នុងការស្វែងរកជីវិកម្មតាមសមត្ថភាពត្រឹមណាដែលធ្វើទៅកើត ដើម្បីយកគ្រឿងឧបភោគ, -បរិភោគមកទំនុកបម្រុងកូនរបស់ខ្លួនជាជាងរូបខ្លួនឯង ហើយគ្មានគិតប្រាថ្នាយកប្រយោជន៍អ្វីអំពីកូនឡើយ រិះរកមធ្យោបាយបែបម៉េចឲ្យតែបុត្រធីតាអស់នោះ ទទួលយកនូវដំបូន្មានដ៏ប្រសើរអំពីខ្លួនដើម្បីឲ្យមានសីលធម៌បរិបូណ៌ឡើង និងទំនុកបម្រុងឲ្យកូនរៀនសូត្រ បានចេះដឹងមានកិត្តិស័ព្ទយស-ស័ក្តិល្បីខ្ចរខ្ចាយដ៏ល្អប៉ុណ្ណោះ; សេចក្ដីនេះ សរឲ្យឃើញថាមាតាបិតាមានធុរៈ ចង់តែឲ្យកូនចេះដឹងនិងឲ្យកូនមានសីលធម៌ដ៏ឧត្ដមនោះឯង ។

បើកូនប្រុសស្រីបានរៀនសូត្រចេះដឹងពូកែហើយ ទាំងបានប្រព្រឹត្តអាចារៈ ដែលមាតាបិតាប្រៀនប្រដៅឲ្យមុតមាំ សមគាត់សែនត្រេកអរហួសប្រៀប ។ កុមារ–រីទាំងឡាយ! តើអ្នកនឹងមានទស្ដីដូចម្ដេច?

មាតាបិតារបស់អ្នកមានគុណូបការៈមកលើអ្នកធ្ងន់សម្បើមអស្ចារ្យ ដូចម្ដេច? បើអ្នកមានកម្លាំងគ្រាន់នឹងជួយផ្ទាស់ធុរៈដ៏លំបាកអំពីមាតាបិតាអ្នកបានហើយ! អ្នកនឹងព្រងើយកន្ដើយឬអ្វី? កិច្ចដែលត្រូវសំដែងកតញ្ញូកតវេទិតបស្នងសងគុណដល់គាត់ អ្នកយល់ថាជាការមិនសំខាន់ ឥតប្រយោជន៍ទេឬអ្វី? បើអ្នកប្រឡេសបើស ឃើសឃ្នងប្រឡាងខាម ធ្វើឲ្យគាត់ព្រួយដោយសារអ្នក ហើយអ្នកនឹងបានសេចក្ដីសរសើរអំពីអ្នកដទៃដែរឬទេ? គេនឹងសំគាល់អ្នកទុកទៅអនាគតថាជាមនុស្សមានភក្ដីស្នេហាចំពោះជាតិ–សាសនា–មហាក្សត្របែបម៉េចទៅ? បើអ្នកធ្វើឲ្យមាតាបិតាអ្នកបង្ហូរទឹកភ្នែករហាមដោយសារអ្នកតាំងពីនេះទៅហើយ!

កុមារ-រីទាំងឡាយ ដែលបានឲ្យមាតាបិតាមានមុខញញឹមដ៏ប្រិមគ្រប់កាល, អ្នកកន្ទៀតជិតឆ្ងាយតែងសរសើរមិនដាច់; បើក្នុងគ្រួសារមានសុជីវធម៌ដូច្នេះ

ហើយ អាចឲ្យគេយល់ថាជាមនុស្សស្នេហាជាតិមួយ ជាក់ស្ដែងផងទៀត ។

ហៃកុមារ-នារីទាំងឡាយ ការធ្វើនូវសង្គមរបស់គ្រួសារឲ្យមានក្លិនក្រអូប, ឲ្យមានពន្លឺភ្លឺថ្លា រាប់ថាជាសញ្ញាបត្រមួយដ៏ប្រសើររបស់អ្នក ; អ្នកណាក៏ដោយចង់តែបែរមុខញញឹមមករកអ្នក គឺចង់តែសេពគប់គាប់ប្រសព្វនឹងអ្នក ៗ ទោះបីអ្នកទៅកន្លែងណា សឹងតែគេមានភក្ដីស្មាម័ក្ដិដ៏ជ្រះថ្លាចំពោះអ្នក ហើយអ្នកនឹងបានសុខភាពស្រួលគ្រប់ពេលា ។

គុណឪពុក ទុកដូចភ្នំ ព្រះសុមេរុ
គុណអ្នកម៉ែ ទុកដូចម- ហាសមុទ្រ
ដែលហូរចេញ ឥតមានល្ហែ ពេញបន្ទុក
គាត់មានមុខ បែរមកយើង ស្រស់ក្ដីថ្លា ។
ដូច្នេះយើង ត្រូវគោរព ឲ្យពេញលេញ
តាមលោកវិ- ញ្ញត្តិទុក កន្លែងមាត្រា
ដើម្បីឲ្យ យើងរាល់គ្នា មានអាចារ
គ្រប់ប្រការ លក្ខណា មាត្រានោះ ។
ហៃកុមារ ទាំងឡាយអើយ! នៅតូចណាស់
គួររវាស ដើររវើ គិតចំលុះ
ចំណាយចិត្ត រៀនវិជ្ជា សាស្ត្រនោះ ១
ត្រូវពារពុះ ពាន់អាយុ នៅពាលា ។
ព្រោះអ្នកប្រាជ្ញ បានកត់ទុក កន្លែងលោកនិត្យ
ថាបេះពិត មកពីសិក្ខ រៀនវិជ្ជា
អ្នកមិនបេះ មកហេតុតែ ខ្ជិលសង្សា
នោះគ្រួសារ មិនអាចខ្ពស់ ទៅមុខបាន ។
ថ្ងៃនឹងយប់ មកដល់ហើយ កន្លងទៅ
ដង្ហើមនៅ ដកចេញចូល តែក្នុងប្រាណ
អ្នកមិនដឹង ក្ដីពិរ៉េន នឹងខ្វះខាន
ប្រាណទុកដូច ស្នប់ជាងដែក ស្រេចហើយណា ។
បើទុកជា មានដង្ហើម ដកចេញចូល
លោកប្រមូល ថាទុកដូច គ្មានខ្លឹមសារ
ព្រោះអ្នកនោះ អវិជ្ជា អត្ថការ
រូបអត្តា ហែងស្គាល់ការណ៍ របស់លោក ។
អនាគត ប្រទេសជាតិ ផ្ដើលើអ្នក
ដោយជាងជាក់ ពិតជាអ្នក បំបាត់រោគ
ដោយសារអ្នក ស្គាល់សិទ្ធិ គ្រប់ប្រយោគ
អ្នកបានព្រោក នូវវិជ្ជា គ្រប់ភាសា ។
ព្រោះជនល្ងង់ គេគោរតែ កន្លះខ្ទង
អ្នកមាំមួន គេកោតតែ ស្រុកអាត្មា
គេបូជា ស្ដេចតែក្នុង រាជវង្ស
អ្នកវិជ្ជា នោះទើបបាន សព្វទីស្ថាន ។
កូនបានកើត ជាមនុស្សហើយ គ្មានវិជ្ជា
ឥតផលា កើតប្រ- យោជន៍ណាបាន
ដូចកែកក្លាក់ តែងពាក់ដោត គ្មានដាច់ខាន
ប្រាណលំបាក ដោយក្ដីទុក្ខ ឈឺវេទនា ។

## មហាយក់-សាមិទ្ធ

សិស្សថ្នាក់ទី ៤ "ក" នៃគ្រឹះស្ថានមធ្យមសិក្សា
បាលី ក្រុងភ្នំពេញ ។

## ជំណឿពីជម្ពូទ្វីប

# សង្ខេបន័យសាសនាព្រាហ្មណ៍

ភិក្ខុ គ. គីឡេង ចិត្តប្បញ្ញោ នៅបណ្ឌិតសភាអន្តរជាតិនៃវប្បធម៌ឥណ្ឌា ក្រុងនាគបុរៈ (ប្រទេសឥណ្ឌា) បានផ្ញើអត្ថបទនេះមកឲ្យសមាគមមិត្តសាលាបាលី ដាក់ការបោះពុម្ពក្នុងទស្សនាវដ្ដីនេះយើងបានចុះផ្សាយតាមអត្ថបទនេះទាំងស្រុងដូចតទៅ៖

ដូចជាយើងទាំងអស់គ្នាបានដឹងច្បាស់ហើយថា សាសនាព្រាហ្មណ៍ជាសាសនាមួយ ចាស់ទុំជាងគេទាំងអស់ក្នុងពិភពលោក ។ ចាស់នេះមិនមែនចាស់លេងៗ ឬបន្តិចបន្តួចទេ គឺចាស់ហួសចំនួន, ចាស់មែនទែន, ចាស់ក្រឹក ទាល់តែពួកអ្នកកាន់សាសនាខ្លួនឯងលែងដឹងថា "សាសនាខ្លួនមានអាយុប៉ុន្មានហើយ" គ្រាន់តែដឹងថា "សាសនារបស់ខ្លួនកើតឡើងដោយអាទិទេព ដែលជាអ្នកបង្កើតផែនទឹកផែនដីសម្រាប់លោកទាំងបី គឺមនុស្សលោក, ទេវលោកនិងនរកលោក" ប៉ុណ្ណោះ) ។

សាសនានេះបានជាគេហៅថា "សាសនាព្រាហ្មណ៍" ព្រោះសាសនានេះលើកដម្កើងតែជនជាតិព្រាហ្មណ៍ថាជាជនប្រសើរផុត ដទៃពីនេះសុទ្ធតែជាជនជាតិថោកទាបទាំងអស់ ។ ក្នុងត្រៃវេទ (គម្ពីរសាសនាព្រាហ្មណ៍មាននិយាយថា "ជនជាតិព្រាហ្មណ៍ជាវង្សស្រឡាយរបស់ព្រះព្រហ្មៗបានបញ្ជូនពួកនេះឲ្យមកកើតក្នុងពិភពលោក ដើម្បីត្រួតត្រាសាសនារបស់ខ្លួន" ។

សាសនានេះគេហៅថា "សាសនាព្រាហ្មញ្ញ ឬព្រាហ្មញ្ញសាសនា" ក៏បាន ព្រោះមានព្រហ្មជាធំ ជាដីដូនដីតារបស់ពួកព្រាហ្មណ៍ ឬនឹងហៅថា "សាសនាឥណ្ឌូ" ក៏បានទៀត ព្រោះជនជាតិដែលកាន់សាសនានេះ បានវាតអាតអំណាចធំៗ មុនដំបូងបំផុតនៅតាមឆ្នេរស្ទឹងសិន្ធុ ហើយស្ទឹងសិន្ធុនេះក្លាយឈ្មោះទៅជាហិណ្ឌូដល់មកសព្វថ្ងៃនេះ ។

ដូច្នេះឈ្មោះទាំងបីដូចខាងលើនេះគឺជាឈ្មោះនៃសាសនាតែមួយនេះឯងតែសព្វថ្ងៃគេច្រើនតែហៅថា "សាសនាហិណ្ឌូ" ៗ ក្នុងសាសនាហិណ្ឌូមានមូតិ ៣ ហៅថាត្រីមូតិ ដែលជាអ្នកធានាអះអាងលើពិភពលោក គឺព្រះឥសូរ ១, ព្រះព្រហ្ម ១, ព្រះវិស្ណុ ១, ។

១- ព្រះឥសូរ ឬហៅព្រះសិវៈក៏បាន, មានភារៈជាអ្នកបំផ្លិចបំផ្លាញលោក មានភ្នែក ៣ មានសក្តិ[1] ឈ្មោះនាងឧមាភោគវតី ឬទុគ៌ាទេវីដែលមានដៃ៨, មានបុត្រច្រើន បុត្រទី ១ ឈ្មោះគណេសៈ មានក្បាលជាដំរី ខ្លួនជាមនុស្ស ។

២- ព្រះព្រហ្ម មានភារៈជាអ្នកបង្កើតលោក ឬត្រូវជួសជុលលោកមានសក្តិឈ្មោះព្រាហ្មណី ឬសរស្វតី (មិនឮថាមានកូនទេ) ។

៣- ព្រះវិស្ណុ មានភារៈជាអ្នកថែរក្សាលោក, មាន

---

១- សក្តិនេះ មានទំនងដូចជា មហេសី ។

សត្តិ ឈ្មោះលក្ស្មី (មិនឮថាមានកូនចៅដែរទេ) ។

ព្រះទាំងពីរអង្គនេះឋិតនៅស្ថានសួគ៌ទាំងអស់ សព្វថ្ងៃកំពុងឃ្លាំចាំមើលការប្រព្រឹត្តរបស់មនុស្ស ។ ព្រះវិស្ណុមានអវតារ ច្រើនបែបច្រើនយ៉ាង គឺជួនកាលទៅជាមច្ឆត្យៈ (ត្រី), ជួនកាលទៅជាកូម៌ៈ (អណ្តើក), ជួនកាលទៅជាវរាហៈ (ជ្រូក) ជួនកាលទៅជា-នរសីហៈ (ខ្លួនជាមនុស្ស ក្បាលជាសត្វសីហៈ) ជួនកាលទៅជាវាមនៈ (មនុស្សតឿ), ជួនកាលទៅជារាមៈ (ព្រះរាមក្នុងរឿងរាមកេរ្តិ៍), ជួនកាលទៅជាបរសុរាមៈ (មនុស្សដែរតែឥតបានការអ្វីទេ) ជួនកាលទៅជាក្រឹស្ណៈ (ព្រះជាបច្ចុប្បន្នរបស់ហិណ្ឌូ) ។ អវតារមានប៉ុណ្ណេះជាដើម សុទ្ធតែជាទូតរបស់ព្រះវិស្ណុ ។

អ្នកកាន់សាសនាហិណ្ឌូចូលចិត្តជឿអំណាចធម្មជាតិ ចូលចិត្តជឿទេវតា ខ្មោច, ព្រាយ, អារក្ស, អ្នកតាណាស់ ។ អ្នកដែលប្រធំប្រធានខាងជឿជាងគេនោះគឺវណ្ណសូទ្រៈពួកនេះចេះតែជឿដោយមិនដឹងឲ្យល់អ្វី ជឿឥតបែបណាស់ បានជាកើតទៅជាមានជំនឿផ្លូវច្នេះ ព្រោះក្នុងសាសនាព្រាហ្មណ៍គេចែកមនុស្សទៅជា ៤ វណ្ណៈ គឺព្រាហ្មណវណ្ណៈ ១, ក្សត្រិយវណ្ណៈ ១, វៃស្យ-វណ្ណៈ ១, សូទ្រវណ្ណៈ (វណ្ណសូទ្រៈ ១,)

១- ព្រាហ្មណវណ្ណៈ មានភារៈខាងការរៀនខ្លួនឯង, បង្ហាត់បង្រៀនអ្នកដទៃ និងការស្វាធ្យាយន៍មន្តអាគម, វេទ, ជាដើម ។

២- ក្សត្រិយវណ្ណៈ មានភារៈជាអ្នកចម្បាំងការពារស្រុកទេស កុំឲ្យសត្រូវចូលមកមើលងាយបាន ។

៣- វៃស្យវណ្ណៈ មានភារៈជាអ្នកលក់ផ្សារ, លក់ចេញទិញចូល, ធ្វើកសិកម្ម ពាណិជ្ជកម្មជាដើម ។

៤- សូទ្រវណ្ណៈ មានភារៈតែខាងទាសកម្មករ, រែក, សែងពុន, កាប់គាស់ជាដើម បានសេចក្តីថា ជាទាសៈទាសីរបស់វណ្ណៈទាំង ៣ ខាងលើ ។ ដោយអាស្រ័យហេតុនេះហើយ បានជាវណ្ណសូទ្រៈនេះថោកទាបណាស់ ហើយមិនមានសិទ្ធិនឹងសេរីភាពចូលទៅរៀនក្នុងសាលារៀន, អង្គុយស្មើ ឬបរិភោគជាមួយនឹងវណ្ណៈឯទៀតបានទេ ។ ព្រោះតែមិនមានការសិក្សានេះហើយ បានជាល្ងង់ខ្លៅណាស់ ចេះតែជឿឲ្យតែព្រាហ្មណ៍ប្រាប់ទោះអ្វីក៏ដោយ ។ ថែមទាំងព្រាហ្មណ៍នោះសោតក៏ណាស់ទៅទៀត មិនចេះនិយាយឬទេសនាប្រាប់គ្នាឲ្យយល់ត្រូវទេ, និយាយតែផ្លូវណាដែលអាចញ៉ាំងវណ្ណសូទ្រៈនេះមិនឲ្យងើបក្បាលរួច; បើមិនប្រាប់គ្នាឲ្យដឹងផ្លូវខុសទេ ក៏មិនប្រាប់ឲ្យស្គាល់ផ្លូវត្រូវដែរ ។ តែអ្នកដែលគេសន្មតថាឋិតនៅក្នុងវណ្ណៈខ្ពង់ខ្ពស់នោះ គេប្រព្រឹត្តកាន់ឫកមារយាទ, កាន់សាសនា, ស្រឡាញ់ផែនទឹកផែនដី ធ្វើការទៅតាមឋានៈគេរៀងៗ ដែលគួរឲ្យសរសើរថាជាមនុស្សជាន់ខ្ពស់ ។

ក្នុងសាសនាហិណ្ឌូ អ្នកបួសជាតិព្រាហ្មណ៍មិនមានការទេសនាប្រៀនប្រដៅអ្នកកាន់សាសនាខ្លួនឲ្យលះបង់លទ្ធិខុសពោលចេញដូចលោកសង្ឃនៅប្រទេសយើងទេ ទោះអ្នកណាប្រព្រឹត្តតាមបែបណាយ៉ាងណាក៏

ដោយស្រេចតែចិត្ត លែងទំដឹងចិត្ត ព្រោះថាបើប្រៀនប្រដៅឲ្យធ្វើត្រូវតែបែបមួយ ពាល់តែកុំឲ្យមានវណ្ណៈដូច្នេះដូច្នោះ នេះឯងទើបហាមាត់និយាយកើត ។ ពួកនេះគ្រាន់តែមានការទេសនាឲ្យជឿទៅតាមុតមាំប៉ុណ្ណោះឯង ឯព្រះពុទ្ធសាសនាយើងវិញ ព្រះអង្គមិនមែនចែកប្រជាជនទៅជាវណ្ណៈដូច្នោះទេ ព្រោះថាទ្រង់អនុញ្ញាតឲ្យមនុស្សទាំងអស់មានជីវិតតែមួយដូចគ្នា ។ កម្ពុជាជាប្រទេសកាន់សាសនាដែលមានបែបផែនតែមួយ ហេតុដូចម្ដេចក៏មានវណ្ណៈ គឺបូកណាទឹងសម័យនឹងគេដែរ?

រឿងបូកណាទឹងសម័យនេះ គួរតែយើងប្រញាប់ប្រញាល់រៀបចំឲ្យបានល្អឆាប់ទៅ ព្រោះជាហេតុនាំឲ្យលិអក់ព័ណ៌ ឬដំបៅសាសនា ទាំងនាំឲ្យខាតប្រយោជន៍ស្រុកទេសទៀត ។ ការនេះពុំគួរនឹងបណ្ដោយឲ្យនៅយូរទេ គោងតែធ្វើទាន់នៅក្ដៅៗ ។

បណ្ដាអវតាររបស់ព្រះវិស្ណុទាំងឡាយនោះ សព្វថ្ងៃហិណ្ឌូទទួលរាប់អានជាងគេតែ ២ ទេគឺ រាមៈ និងក្រឹស្ណៈ ដោយហេតុថាអវតារដទៃពីនេះមិនត្រូវបែបផែន, មិនមែនជាមនុស្សជាតិ ។ រាមៈដែលបានទៅជាគេគោរពរាប់អានដល់ម្ល៉េះ, ព្រោះបានច្បាំងឈ្នះស្ដេចក្រុងលង្កាគឺព្រះរាពណ៍ ហៅព្រះបាទទសមុខឬទសកណ្ឋក៏បាន ។ ក្នុងពេលដែលយកជ័យបានហើយនោះ កេរ្តិ៍ឈ្មោះរាមៈល្បីល្បាញ ខ្ចរខ្ចាយទៅក្នុងពិភពលោកទាំងមូលមានប្រទេសកម្ពុជាយើងជាដើម ដែលយើងហៅថា "រឿងរាមកេរ្តិ៍" សម្រាប់និយាយព្រោកប្រាជ្ញឲ្យអ្នកស្ដាប់ឬសម្រាប់លេងល្ខោន ឯក្រឹស្ណៈវិញ ដែលបានទៅជាល្បីល្បាញនឹងគេដែរ ព្រោះមានបញ្ញាមុះមុតណាស់ បានជ្រោមជ្រែងត្រកូលស្ដេចទាំងពីរខាងគឺកៅរវៈ និងបាណ្ឌវៈ ដែលច្បាំងនឹងបងប្អូនគ្នាឯងឲ្យមានសន្តិភាព ដោយចូលដៃខាងពួកបាណ្ឌវៈ តាំងខ្លួនធ្វើជាមេទ័ពបង្ហាត់បង្រៀនយុទ្ធសាស្ត្រ ដើម្បីច្បាំងឲ្យមានជ័យឈ្នះពួកកៅរវៈ ។ ពេលច្បាំងគ្នា ពួកបាណ្ឌវៈឈ្នះមែន ឯក្រឹស្ណៈក៏ជាប់ល្បីល្បាញថាជាអ្នកតំណាងអាទិទេពតាំងពីនោះមក ។ (រឿងនេះមានសេចក្ដីពិស្ដារនៅក្នុងមហាភារតជារឿងពិសិដ្ឋទី ១ ក្នុងសាសនាហិណ្ឌូ តមកបានដល់មករឿងរាមកេរ្តិ៍) ។ បើយើងរំរៀនសាសនាយើងឲ្យបានចេះមែនទែន ហើយចេញដើររៀនសាសនាគេទៀត ប្រាកដជាសប្បាយចិត្តណាស់ក្នុងការដដែកសាសនានេះ, ទោះបីក្នុងសាសនាណាក៏ដោយក៏យើងមិនចាញ់ប្រៀបគេដែរ ។

សព្វថ្ងៃគេឃើញតែរូបព្រះរាមជាមួយនាងសិតា ក្រឹស្ណៈជាមួយនាងរាធានៅដេរដាសពាសពេញក្នុងវិហារហិណ្ឌូ ។ ក្រៅពីនេះមានរូបដទៃខ្លះដែរ តែតិចតួចណាស់ ដូចជាអាទិទេពពាអគ្គិខាងដើមជាដើម ។ ការកាន់សាសនាហិណ្ឌូមានកិច្ចរវល់សន្ធឹកសន្ធាប់ណាស់ មនុស្សម្នាក់ៗ រវល់នឹងបូជាបន់ស្រន់តែរាល់ថ្ងៃ ។ សូមប្រគេនជូនពិធីខ្លះជាឧទាហរណ៍ដូចតទៅនេះ

## ការគោរពសាសនា

ក្នុងសាសនាហិណ្ឌូ មានការបន់ស្រន់អំពាវនាវកេ

ទំពាំងច្រើនបែបច្រើនយ៉ាងណាស់ អ្នកកាន់សាសនាហិណ្ឌូគោរពតាមពេលខ្លះសម្រាប់ថ្វាយបង្គំព្រះអាទិត្យ, ព្រះចន្ទ, អាទិទេព, ធម្មជាតិ ឬក៏សម្រាប់ផ្លូតទឹកលាងបាបជាដើម ។ ការប្រព្រឹត្តិបែបនេះ ដោយហោចណាស់ក៏អស់ ១៥នាទី ឬកន្លះម៉ោងដែរ, បន់ស្រន់នៅទីងផ្ទះក៏បាន ទៅឯវិហារក៏បាន ។ ពិធីធ្វើនៅផ្ទះដូច្នេះគឺពេលព្រលឹមឡើងថ្ងៃរះហើយ គេយកទឹក ១ ផ្តិលមកឈរនៅមុខផ្ទះ ឬទីណាមួយ, បែរមុខទៅទិសខាងកើតចំទៅព្រះអាទិត្យ ឈរជើងទំមគ្នា ដៃទាំងពីរលើកទឹកផ្តិលឡើងដល់ថ្ងាសស្រោចចុះទៅលើដីបន្តិចហើយដាក់ទឹកផ្តិលនោះផ្ទុំត្រង់ថ្ងាសគិតសញ្ជឹងទៅព្រះជាម្ចាស់របស់គេណាមួយ ដែលគេចូលចិត្ត ទោះជាព្រះអាទិត្យក៏ដោយ, ព្រះចន្ទក៏ដោយព្រះរាមក៏ដោយ, ក្រឹស្ណៈក៏ដោយ, ហនុមានក៏ដោយ, ព្រះព្រហ្មក៏ដោយ, ព្រះឥសូរក៏ដោយ, ព្រះវិស្ណុក៏ដោយ, ឬទេវតាណាមួយក៏ដោយ ។ បន្ទាប់ពីនេះទៅ គេបង្វិលខ្លួន ៣ ជុំ ហើយដាក់ទឹកផ្តិលចុះមកវិញទន្ទឹមនឹងទ្រូងស្រោចទៅលើដីបណ្តើរនិយាយបួរបាច់ប្រាប់ទេពនោះខ្លះបណ្តើរ, លុះស្រោចបានពាក់កណ្តាលហើយគេយកដៃស្តាំចាប់ក្បាលទឹកដែលកំពុងហូរចុះពីផ្តិលនោះ, គ្រវាត់វិលជុំក្បាល ១ ជុំ ហើយបើនៅសល់ប៉ុន្មានត្រូវយកមកផឹក បន្ទាប់ពីនោះទៀតគេយកដៃជ្រលក់ក្នុងទឹក, ផ្តិលនោះហើយផ្ចិតទឹកឲ្យខ្ទាតទៅមុខពីរ-បីដំណក់ហើយយកដៃមកស្ទាបទ្រូង, ស្ទាបថ្ងាសស្ទាបភ្នែកទាំងសងខាង ។ បើមាននៅសល់ទឹកក្នុងផ្តិលទៀតគេក៏ចាក់ចោលទៅ ប៉ុណ្ណេះជាដើមឈ្មោះថាចប់, ការបន់ស្រន់នៅផ្ទះ ។

ឯពិធីនៅវិហារវិញ ក៏មានអាការគួរឲ្យចង់មើលណាស់ដែរគឺ នៅក្នុងវិហារហិណ្ឌូមានអ្នកបួសនៅចាំជានិច្ចតាមវិហារតូចធំ ។ អ្នកដើរទៅកាន់វិហារមានកាន់ផ្កា, ទៀន,ធូប,ខ្លះទៅផងដើម្បីបូជា; ទៅដល់ហើយគោងគោះជួងឬគាំងមួយម៉ូង ។ កាលបើដល់ម៉ោងហើយគោងប្រុងប្រៀបខ្លួនក្រោកឈរទាំងអស់គ្នាជួយបន្ទរតាឬទះដៃ; រគាំងជួងប៉ុន្មានត្រូវគោះឡើងទាំងអស់ឲ្យឮសូរតែមួយ ព្រោះពេលនោះជាពេលបូជាធំ ។ ឯអ្នកបួសព្រាហ្មណ៍ដែលមានកំប៉ោយពីក្រោយ, ប៉ាតជ័រអង្គុលក្រហមឆ្មៅពេញថ្ងាស នៅចំពីមុខទេវរូបដុតទៀន ៣ ដើមលើក្នុងថាសមួយតូចមានប្រេងដូងខ្លះផង កាន់កណ្តឹងមួយក្រោកឈរឡើង សំដែងអាការឲ្យឃើញថា "ការបូជាបែបហ្នឹងស័ក្តិសិទ្ធណាស់" ។ កាលបើស្គររគាំង, ជួង, ទះដៃឮសូរតែមួយហើយ អ្នកបួសព្រាហ្មណ៍ក៏ឈរពោះជើងស្តាំទៅមុខបន្តិច ដៃស្តាំកាន់ថាសទៀន, ដៃឆ្វេងកាន់កណ្តឹងអង្រួនបណ្តើររបង់បោយបណ្តើរ យោលបែបទ្រង់រង្វិល ១បន្តិច; ឯដៃដែលកាន់ថាសទៀននោះ លើកចុះលើកឡើង, ខ្ពស់ទាបៗដាក់ទៅលើសិរសាទេវរូបបន្តិច, ទៅត្រង់ទ្រូងបន្តិចត្រង់ជើងបន្តិច, ក្រោយខ្នងបន្តិច, ពោះបន្តិច, ទាំងខ្នងគេទៀតសោតក៏ធុនបន្តិច ជើងបន្តិច, បែបស្ងួតបន្តិច

គាចបន្តិច, ដើរចូលទៅបន្តិច ថយមកវិញបន្តិច, គាច់រាងពៅទ្រង់ញ័រខ្លួនបែបដូចជាសិដៃងឲ្យឃើញថា "ខ្ញុំទៅៗ ជិតបានត្រាស់ដឹងហើយ ព្រះយ៉េនតូវែកណាស់" បើប្រៀបមកប្រទេសយើងថាដូចជាជាន់គាក្យ ឬអ្នកតា ៗ រាល់តែ ១៥ នាទីប៉ុណ្ណោះ ការបូជានេះក៏ចប់ស្ងួតគាំង, ជូនឈប់ដំណាលគ្នា ដោយអ្នកបួសឲ្យសញ្ញា ហើយគេចូលទៅសុំស្លាបថាសទៀននោះបន្តិចម្នាក់ ដើម្បីជាសិរីសួស្តីរបស់គេ ៗ កាលបើបានស្លាបហើយ គេក៏វិលត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន, នេះសន្មតថាចប់ការបូជានៅវិហារ ១ ថ្ងៃ ៗ

បើនិយាយតាមផ្លូវវេទ ព្រះសម្មាសម្ពុទ្ធជាម្ចាស់របស់យើង ក៏គេរាប់ថាជាអវតាររបស់ព្រះវិស្ណុដែរ តែហិណ្ឌូមិនទទួលដឹងគុណទេ ព្រោះថាព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូទ្រង់សំដែងធម៌លាយសិទ្ធិនិងសេរីភាពរបស់សាសនាហិណ្ឌូទាំងស្រុងតែម្តង, ញ៉ាំងប្រជាជនឲ្យមានអធិបតេយ្យស្មើគ្នា, យកធម្មាធិបតេយ្យថាជារដ្ឋធម្មនុញ្ញ ហើយព្រះអង្គទ្រង់បំភ្លឺតទៅទៀតថា ការប្រព្រឹត្តិស៊ីស្មៅ, ផឹកតែទឹក ស៊ីតែបន្លែ, ប្រឡាក់ផេះខ្លួនប្រាណដើម្បីឲ្យស្អុតកិលេស, ដេកហាលថ្ងៃឲ្យរលីងស្ងួតទ្រុះតណ្ហា, ការលើកដៃឲ្យស្វិតដើម្បីឲ្យគេស៊ើប, ការប្រព្រឹត្តិអចេល (អាក្រាត), ការថ្វាយបង្គំធម្មជាតិ, ថ្វាយបង្គំភ្លើង, សំពះអនេកអាទិទេព, សម្លាប់សត្វយកមកបូជាយញ្ញ, ការចែកវណ្ណៈប៉ុណ្ណោះជាដើមសុទ្ធតែជាការឥតប្រយោជន៍ រាប់ចូលក្នុងអត្តកិលមថានុយោគនិងកាមសុខល្លិកានុយោគទាំងអស់ ៗ នេះហើយដែលញ៉ាំងអ្នកកាន់សាសនាហិណ្ឌូឲ្យរឹងរឹតតែក្តៅខ្លាំងឡើងដោយហេតុថា ព្រះពុទ្ធមិនបេះអនុវត្តទៅតាមច្បាប់ដើមរបស់គេ, មិនស្គាល់លទ្ធិស្រុកទេស, បេះតែប្រឆាំង, បដិសេធសាសនាគេចោលទាំងស្រុង ៗ ឥឡូវអ្នកកាន់សាសនាហិណ្ឌូទៅជានាំគ្នាចោទថា សមណគោតមជាមនុស្សអកតញ្ញូទៅវិញ ព្រោះគ្មានដឹងឧបការគុណរបស់អាទិទេពដែលជាធំសោះឬមិនដែលពុទ្ធទេសនាសរសើរអាទិទេពម្តងសោះ ៗ បើមិនចង់សរសើរដោយខ្លួនឯង ក៏គួរតែឲ្យសិស្សគណខ្លួនសរសើរដែរ; បានកើតមកនៅក្នុងទឹកដីរបស់ព្រះវាម្ចាស់ហើយបែរជានិយាយបំបាត់ឈ្មោះព្រះវាម្ចាស់ចោលទៅវិញ" ៗ

យើងជាពុទ្ធសាសនិកជនមិនរាប់ថាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ជាអវតារ (ជាអ្នកនាំសារពបរ, អ្នកបំរើ, ជារាជទូត) របស់ព្រះវិស្ណុទេ ព្រោះយើងមានសទ្ធាជឿជាក់ទៅហើយថា ព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូគ្រប់ព្រះអង្គដែលខំបំពេញបារមីទាំងឡាយដើម្បីសព្វញ្ញុតញ្ញាណនោះ មិនមែនដើម្បីធ្វើកូនឈ្នួលឬស៊ីឈ្នួលអ្នកណាទេ គឺព្រះអង្គត្រាស់ដឹងឡើងក្នុងលោក ដើម្បីជាហិតានុហិតដល់សត្វលោកប៉ុណ្ណោះ ៗ សូម្បីព្រះសម្មាសម្ពុទ្ធទាំងឡាយដែលកន្លងទៅហើយក្តី, ក្នុងបច្ចុប្បន្ននេះក្តី, នឹងមានមកក្នុងកាលជាអនាគតក្តីក៏ដូចគ្នា ៗ ហេតុដូច្នេះព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ មិនដែលអួតថាជាកូនឈ្នួលអាទិទេព មិនដែលធានាអះអាងពិតពលោកទេ

ព្រោះថាកិរិយានិយាយបន្ទឹកវាបែបនេះ ជាការមិនសមហេតុមិនសមផល ។ បើការណាប្រាសចាកហេតុហើយ ប្រាកដជាមិនមានផលទេ, បើវៀរចាកផលហើយ មុខជាមិនមានហេតុ ឬក៏ប្រាសចាកហេតុនិងផលទាំងពីរ ឥតបាននៅជាអ្វីឡើយ ។ កិរិយានិយាយបែបនេះហើយដែលជាអគ្គិការ ឬ ផ្ទុយរបស់អរិយសច្ចធម៌ ជាធម៌រកផលតែពុំមិនកើត; ជាធម៌ដែលព្រះអង្គទ្រង់សំដែង ២៤៩៨ ឆ្នាំព្រាយមកហើយផ្តាច់ជើងអាទិទេពជាន់ចាស់និងជាន់ថ្មីទាំងអស់ ។

ក្នុងសាសនាទាំងអស់ក្នុងពិភពលោក លើកលែងតែព្រះពុទ្ធសាសនាមួយចេញ ដែលជាសាសនាមិនប្រើអំណាចលើពិភពលោក ដទៃពីនេះសុទ្ធតែនិយាយអាងទៅលើអាទិទេពទាំងអស់; កាលបើនិយាយឡើងសុទ្ធតែយកអាទិទេពជាអាទិ៍ ។ ក្នុងសាសនាទាំងនោះ សុទ្ធតែមានការបរិយាយពីព្រះអនាគតរៀងៗខ្លួនទៀត ។ អនាគតព្រះទាំងនោះ នឹងមកប្រៀនប្រដៅដើរតាមវិទ្យស្រឡាយព្រះបច្ចុប្បន្នគេទៀតជាប្រាកដ ។ ឯក្នុងព្រះពុទ្ធសាសនាយើងវិញ ក៏មានព្រះជាអនាគតនឹងកើតដែរ គឺព្រះអរិយមេត្តេយ្យនោះឯង; តែព្រះអង្គដែលនឹងមានមកនោះ មិនមានឈានាឬមកចុះពិភពលោកដូចគេទេ គឺព្រះអង្គមកដើម្បីជាពន្លឺសតិបញ្ញារបស់យើងគ្រប់គ្នា ដែលងងឹតងងល់វង្វេងវង្វាន់ក្នុងវដ្ដសង្សារ ព្រោះតែជឿអាទិទេពដោយមិនដឹងអ្វីនោះ ។

ហេតុនេះយើងដែលជាអ្នកកាន់ព្រះពុទ្ធសាសនាមិនត្រូវរវល់សំពះអង្វរព្រះអាទិទេពទេ ចូរយើងទាំងអស់គ្នាទាំងបព្វជិតទាំងគ្រហស្ថទាំងប្រុសទាំងស្រី ខំប្រឹងប្រែងសិក្សារៀនសូត្រសាសនាយើងឲ្យមែនទែន ជួយប្រកាសសាសនាយើង ឲ្យមានពលភាពបរិបូណ៌ឡើងទាំងក្នុងប្រទេសទាំងក្រៅប្រទេស ។ ចូរយើងខំធ្វើការបំរើជាតិ, សាសនា នឹងមហាក្សត្រយើងឲ្យបានត្រឹមត្រូវតាមសុចរិតយុត្តិធម៌ឡើង ។ ចូរយើងខំការពារតាំងអធិដ្ឋានចិត្តឲ្យបានត្រឹមត្រូវតាមកម្មវិធីត្រៃសរណដ្ឋានឡើង ។ ចូរយើងសម្រាកការប្រណែនផ្តួនាឈ្នានីសគ្នានឹងគ្នាម្តងសិន ។ ចូរយើងបញ្ឈប់ការតិះដៀលមើលងាយគ្នាសិន ។ ចូរយើងខំបំប៉នធម៌សាមគ្គីឲ្យកើតថ្លោសឡើង ។ ចូរយើងខំអានទស្សនាវដ្ដីអក្សរសាស្ត្រយើង, សាសនាយើង, ជួយគ្នាយើងឲ្យយើងមានសមត្ថភាពគ្រប់គ្រាន់ឡើង ។ ចូរយើងជួយបង្កើតសមាគមឲ្យបានធំៗ ឡើងព្រមទាំងជួយវាត់គ្នាយើងឲ្យទៅសិក្សារៀនសូត្រនៅនានាប្រទេស ឬឲ្យទៅទេសនានៅនានាប្រទេស ប្រៀនប្រដៅប្រជាជនផ្សាយសាសនាយើងឡើង ដើម្បីឲ្យសមឈ្មោះថាយើងជាកុលបុត្រកើតមកជាមនុស្សក្នុងលោក កាន់ព្រះពុទ្ធសាសនាមួយយ៉ាងខ្ពង់ខ្ពស់នឹងដើម្បីឲ្យស្របតាមគន្លងឱវាទរបស់ព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូយើងថា :

"ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ! បបួលគ្នាចេញទៅកាន់ចារិកទៅ ( ចារិកគឺទីដែលគេចូលចិត្តទៅ ឬទីដែលមានប្រជាជនប្រជុំគ្នាច្រើន) ដើម្បីប្រយោជន៍

សេចក្ដីសុខ, សេចក្ដីចំរើនដល់ទេវតានិងមនុស្សទាំងឡាយ ព្រោះថាធម៌ដែលតថាគតសំដែងហើយនោះជាព្រហ្មចរិយធម៌ដ៏បរិសុទ្ធ មានលំអបទខាងដើម, កណ្ដាល និងខាងចុងព្រមទាំងអត្ថនិងព្យញ្ជនៈ ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ! ចូលរៀនឲ្យបានចេះចាំស្ទាត់ហើយចេញទៅប្រកាស " ។

ភិក្ខុ គួច–តឺឡេង បិតប្បញ្ញោ
ថ្ងៃទី ២៨ មិថុនា ព.ស.២៤៩៨

International Academy of Indian Culture
Nagpur India

x x
x

## កម្មវិធីវិសាខបូជាសម្រាប់ ព.ស. ២៥០០

(ប្រែពីទស្សនាវដ្ដីមហាពោធិសមាគមជម្ពូទ្វីប ឆ្នាំទី ៦៣ លេខពិសេសសម្រាប់វិសាខបូជា ឆ្នាំ ១៩៥៥)

កាលពីថ្ងៃទី ២១ ខែមករា ១៩៥៥ នេះ គណៈកម្មការមហាពោធិសមាគមជម្ពូទ្វីប បានប្រជុំនិយាយអំពីរឿងធ្វើវិសាខបូជាជាគម្រប់ ព.ស. ២៥០០ ឆ្នាំក្រោយ ហើយបានសម្រេចសេចក្ដីដូចតទៅនេះ

១- កន្លែងសម្រាប់ពិធីបុណ្យនឹងរៀបចំតាក់តែងនៅពុទ្ធគយា (គយាសីសប្រទេស) ។ ពិធីបុណ្យនឹងចាប់ផ្ដើមតាំងពីថ្ងៃពេញបូណ៌មីខែវិសាខឆ្នាំ ១៩៥៦ ទៅរហូតដល់ហេមន្តរដូវ; ការនេះនឹងវែលលកទៅតាមដំណើរចំណង់នៃអ្នកពុទ្ធបូជនីយេសកជនរាំងប្រទេសដែលគួរនឹងបញ្ចប់នៅថ្ងៃខែណាមួយ ។ ពិធីបុណ្យនេះនឹងរៀបចំនៅក្រោមអធិបតេយ្យភាពនៃប្រធានាធិបតីជម្ពូទ្វីប, ដុកទ័ររាជេន្ទ្របសាទ ហើយមហាពោធិសមាគមនឹងធ្វើសេចក្ដីនិមន្តនិងអញ្ជើញនាយករដ្ឋមន្ត្រីជម្ពូទ្វីប នឹងនាយករដ្ឋមន្ត្រីជាពុទ្ធសាសនិកបរទេសទាំងឡាយទៀត ។

២- តាំងទស្សនីយភាពព្រះពុទ្ធសាសនា (Exhibition) បង្ហាញដល់ប្រជាជនទាំងឡាយ ដោយរួបរួមដៃជាមួយនឹងប្រទេសជាពុទ្ធសាសនិកទាំងឡាយ ។

៣- បោះសៀវភៅឈ្មោះ "ព្រះពុទ្ធសាសនាជាគម្រប់ ២៥០០ ឆ្នាំ" ផ្សាយប្រហែលជា ២ ឬ ៣ ក្បាលទើបបប់ ដែលមានប្រាប់ហេតុផលប្រវត្តិសាស្ត្រព្រះពុទ្ធសាសនាដោយសព្វគ្រប់ ។

៤- បោះព្រះត្រៃបិដកភាសាបាលីផ្សាយជាអក្សរទេវនាគរី នឹងប្រែទៅជាភាសាហិណ្ឌី នឹងភាសាអង់គ្លេស (បេង្គាល់) ។

## កម្មវិធីដោយឡែក

១- ធ្វើសញ្ញាប័ត្រពិសេសសម្រាប់ចុះឈ្មោះពុទ្ធិកសមាជិករបស់មហាពោធិសមាគមជាគម្រប់ ព.ស. ២៥០០ ឆ្នាំ ។

២- កសាងបំពេញវិជ្ជាស្ថានវប្បធម៌នឹងការឲ្យធម៌សម្រាប់ពុទ្ធសាសនិករាំងប្រទេស នៅក្រុងកាលកត្តា ។

៣- កសាងបង្កើតវិទ្យាល័យពុទ្ធសាសនា ក្រុងពារាណសី ។

៤- កសាងឧបោសថាគារនឹងមជ្ឈមណ្ឌលរបស់សមាគមនៅពុទ្ធគយា ។

៥- កសាងធម្មសាលានឹងសូមអញ្ជើញពុទ្ធបូជនីយេសកជនទាំងឡាយមកពិនិត្យនឹងថ្វាយបង្គំពុទ្ធបូជនីយដ្ឋានក្នុងជម្ពូទ្វីប ។

មហាពោធិសមាគម សូមនិមន្ត-អញ្ជើញព្រះតេជៈព្រះគុណ–អស់លោក-អ្នកសប្បុរសប្រុសស្រីទាំងឡាយ មកកាន់ទីប្រជុំក្នុងពេលនោះកុំខាន ដើម្បីជាសេចក្ដីរុងរឿងរបស់ព្រះពុទ្ធសាសនា ។

x x

x

## សេចក្ដីបញ្ជាក់ និងយល់ឃើញផ្ទាល់ខ្លួន

កាលបើមហាពោធិសមាគមបានសម្រេចកម្មវិធីបុណ្យវិសាខបូជាដូចខាងលើនេះស្រេចហើយ រដ្ឋាភិ–បាលជម្ពូទ្វីប បន្ទាប់មកមិនយូរប៉ុន្មាន ក៏បានសម្រេចជាឯកច្ឆន្ទ ហើយផ្សាយតាមផ្ទៃកាសែតប្រាប់ប្រជាជនថា: “រដ្ឋាភិបាលជម្ពូទ្វីប នឹងចំណាយប្រាក់ថវិកាជាតិ ៥.០០០.០០០ (៥ លាន) រូពីយ៍សម្រាប់ពុទ្ធវិសាខបូជាជាគម្រប់ ព.ស. ២.៥០០ ក្នុងឆ្នាំ ១៩៥៦ ខាងមុខនេះ ដើម្បីជាកិត្តិយសរបស់ជម្ពូទ្វីប” ។

ជម្ពូទ្វីបមិនមែនជាពុទ្ធសាសនិកប្រទេសទេ តែរដ្ឋាភិបាលគេបានសម្រេចថា នឹងចំណាយដូចខាងលើនេះ ចំពោះព្រះពុទ្ធសាសនា យើងគួរគិតថា: ‘‘តើរដ្ឋាភិបាលក្ដឹងម្ដេចក៏ធ្វើយ៉ាងនេះ ?” ខ្វះឬទេ? កាលបើយើងបានគិតរួចហើយ តើរដ្ឋាភិបាលយើងគួរចំណាយប្រាក់ថវិកាជាតិសម្រាប់វិសាខបូជាឆ្នាំក្រោយនៅប្រទេសយើងនេះប៉ុន្មានដែរ? ឬមានគ្រោងការថានឹងរៀបចំពិធីបុណ្យបែបណាដែរ? បើប្រទេសយើងជាប្រទេសកាន់ព្រះពុទ្ធសាសនាទាំងស្រុង ព្រមទាំងមានគ្រោងទុកក្នុងរដ្ឋធម្មនុញ្ញថា: “ព្រះពុទ្ធសាសនាជាសាសនាសម្រាប់កម្ពុជរដ្ឋ” ផង ។

វិសាខបូជានៅឆ្នាំខាងមុខនេះ មិនមែនតែជម្ពូទ្វីបទេ ដែលត្រូវផ្អើលជ្រួលជ្រើមក្រៃ សូម្បីតែប្រទេសតូចតាចដែលមានព្រះពុទ្ធសាសនារលីបរលាប ក៏ផ្អើលថាត្រូវរៀបចំវិសាខបូជាឲ្យអ៊ឹកអធឹកដែរ ព្រោះថាព្រះពុទ្ធសាសនាជាសាសនាស្វែងរកសន្តិភាពនិងមនុស្សធម៌ឲ្យមនុស្សមែនៗ ។

ជយោ ! ព្រះពុទ្ធសាសនា !

មួយវិញទៀត ខ្ញុំសូមប្រគេនជំរាបថា ការសរសេរឆ្នាំសាសនានៅប្រទេសយើងនឹងប្រទេសដទៃ មានការខុសគ្នា ១ ឆ្នាំ គឺប្រទេសយើងសព្វថ្ងៃសរសេរតែ ២៤៩៨ ទេ, នៅប្រទេសឯទៀតគេសរសេរថា ២៤៩៩ ហើយ ព្រោះគេរាប់ឆ្នាំថ្មីនេះថា “មួយ” ទៅហើយ ទោះបីមិនទាន់ដល់ទីបំផុតក៏ដោយ ។ ឯនៅប្រទេសយើងវិញ ទាល់តែសករាជនោះគន្លងផុត ១ ឆ្នាំ ១ ទើបរាប់ថា “មួយ” បាន, តែខ្មែរយើងទៅជានិយមរាប់អាយុមនុស្សដែលមិនទាន់គន្លងផុតថា “មួយ” ទៅវិញ. ហេតុដូចម្ដេចក៏មិនរាប់អាយុសាសនាដែលទើបចូលមកថ្មីនេះថា “មួយ” ផង ឬក៏មានទាស់ត្រង់ណា? ។ ចុះបើមានគេសួរថា ចាំ

ចាំបាច់ធ្វើឲ្យត្រូវនឹងគេធ្វើអ្វី, ទុកតាមទម្លាប់ទៅមិនកើតឬអ្វី, មានខាតត្រង់ណា? សួរដូច្នេះក៏ចេះតែបានដែរតែថាចង់ឲ្យត្រូវគ្នាបានជាសុំស្នើយោបល់ ព្រោះធ្វើត្រូវគ្នាជាការល្អ; ទាញឧទាហរណ៍មកថាឆ្នាំខាងមុខនេះប្រទេសជាពុទ្ធសាសនិកទាំងប៉ុន្មានក្នុងពិភពលោកនឹងរៀបចំតាក់តែងពិធីបុណ្យវិសាខបូជាទទួលព.ស. ២៥០០ ដោយស្រុះគ្នា បើប្រទេសយើងនៅតែមិនរាប់ឆ្នាំថ្មីនេះបញ្ចូលផងទេ យើងនឹងត្រូវបង្អង់ដល់ឆ្នាំក្រោយមួយទៀត ហើយនឹងធ្វើតែម្នាក់ឯងផង ។ ហេតុនេះ បើរាប់ឆ្នាំថ្មីនេះបញ្ចូលឲ្យទៅជា២៤៩៩ផងជាការល្អ បើតាមយោបល់ផ្ទាល់ខ្លួនខ្ញុំ ។ បើយើងរាប់បញ្ចូលទៅក៏មិនជាបាបអ្វីដែរទេគឺត្រូវហើយ ព្រោះត្រូវតាមរបៀបរាប់អាយុនៅប្រទេសយើងផង ត្រូវតាមរបៀបសាសនាក្នុងលោកទាំងអស់ផង ។

ម្យ៉ាងទៀត បើប្រទេសយើងសុខចិត្តរាប់បញ្ចូលដូច្នេះ ដល់ឆ្នាំក្រោយប្រទេសទាំងអស់ក្នុងលោកធ្វើវិសាខបូជាទៅ ហាក់ដូចជាធ្វើអភិសេកដំឡើងព្រះពុទ្ធសករាជរបស់ប្រទេសយើងផងដែរ ។

ហេតុដូច្នេះ ការនេះ ស្រេចតែអ្នកប្រាជ្ញរាជ-បណ្ឌិតទាំងឡាយ ដែលត្រូវប្រជុំគ្នាហើយអនុម័តសម្រេចទៅទៀតទេ ព្រោះឆ្នាំក្រោយនេះជាឆ្នាំដែលប្រជាជនក្នុងសាកលលោកនឹងក្រោកឈរឡើងដេញតាមចាប់ស្មើព្រះពុទ្ធសាសនា “ព្រមទាំងជាឆ្នាំដែលខ្មែរយើងធ្លាប់និយាយតែរាល់មាត់ចេះចាំជាក់មកថា: “ដល់ពាក់កណ្ដាលសាសនាហើយ” ផង ។

ជយោ! សករាជព្រះពុទ្ធសាសនា!

ភិក្ខុ ឌួច – គីឡេង បិតបញ្ញា

ថ្ងៃទី ១៦ ខែកក្កដា ២៤៩៨/១៩៥៥

International
Academy of Indian Culture
Nagpure
India

x x

x

## នរក-សួគ៌មានមែនឬ?




បញ្ហានរក–សួគ៌ នាំឲ្យរំជាប់ចិត្តជាប់គំនិតយូរណាស់មកហើយ ដោយធ្លាប់ឮការជជែកគ្នាមិនដាច់ស្រេច ចំពោះមតិពីរបែប គឺ:

១– នរក–សួគ៌មានតែឈ្មោះ ជាគ្រឿងប្រតិស្ឋរបស់គន្ថរចនាចារ្យ ដើម្បីបំភ័យពពួកជនកុំឲ្យប្រព្រឹត្ត

អំពើអាក្រក់, កំឡាពពួកជនឲ្យខិតខំកសាងសេចក្ដីល្អ ។ តាមពិត នរក—សួគ៌ នៅក្នុងចិត្ត ។

២— នរក-សួគ៌ មានពិតប្រាកដ នរកជាកន្លែងទទួលទុក្ខនៃអំពើអាក្រក់ សួគ៌ជាទីសោយសុខនៃអំពើល្អ ។

៣— នរក-សួគ៌ មានប្រាកដ ទាំងក្នុងចិត្តទាំងក្នុងលោកខាងមុខ ។

អ្នកប្រកាន់វាទទាំង ៣ យ៉ាង សុទ្ធតែអាងដល់គម្ពីរនឹងជាតកជាភស្តុតាងដូចគ្នា ជាហេតុនាំឲ្យកើតសេចក្ដីសង្ស័យចំពោះរឿងនេះពន់ពេក ក្នុងផ្ទៃព្រះពុទ្ធសាសនាដូចគ្នា ម្ដេចក៏មានការយល់ដទៃពីគ្នាដូច្នេះ ។

លុះពួកមិត្តភក្ដិប្រាប់ថា ប្រស្នានេះ លោក សុខ—សារិទ្ធ បានយកទៅផ្សាយចុះក្នុងទស្សនាវដ្ដីមិត្តសាលាបាលី លេខ ១០-១១-១២ ឆ្នាំ ១៩៥៤ ខ្ញុំមានសេចក្ដីត្រេកអរជាទីបំផុត ដោយសង្ឃឹមថាមុខជានឹងបានក្ដីច្បាស់ក្នុងរឿងនេះជាពុំខាន ព្រោះជាការផ្សាយក្នុងអង្គការដែលគួរឲ្យជឿបាន ។

តែកាលអានអត្ថបទនោះចប់ ខ្ញុំកើតធុញចិត្តធុញគំនិតជាពន្ទុក ដោយកាន់តែកើតសេចក្ដីសង្ស័យច្រើនឡើង ព្រោះបើល្បងពិចារណាតាមលំអានអ្នកនិពន្ធឲ្យល្អិតល្អន់ទៅ គឺនាំឲ្យយល់វែងឆ្ងាយណាស់ រហូតដល់បែកយោបល់ផ្ទុយនឹងពុទ្ធសាសនាស្រឡះ ស្ទើរតែនឹងទៅជាមិច្ឆាទិដ្ឋិក៏សឹងបាន ។ ខ្ញុំបារម្ភក្រែងអ្នកអានដទៃល្បងពិចារណាដូចខ្ញុំហើយធ្លាក់ដល់ថ្នាក់ដូចគ្នា ទើបខ្ញុំទាញដងប៉ាកាសរសេរមកបញ្ជាក់សួរលោកបណ្ណាធិ—ការឲ្យបានច្បាស់សេចក្ដី ក្រែងលោកបណ្ដោយឲ្យចុះរឿងនរកសួគ៌ក្នុងទស្សនាវដ្ដីរបស់លោក ដោយចង់លចិត្តអ្នកអានតាមបែបបូ "ប្រចាំរឿងចិត្តសប្បុរសនឹងកតញ្ញូ" ដែរ តែបើជាដូច្នោះមែន ក៏ជាលចិត្តនាំឲ្យលង់ហើយ តាមយោបល់របស់ខ្ញុំ ។

អ្នកនិពន្ធរឿងនរក-សួគ៌បានតាំងគោលការណ៍ថា ក្នុងគម្ពីរពុទ្ធសាសនាមានរឿងខ្លះនឹងប្រកាន់ទុកជារឿងពិតទាំងអស់ពុំបាន "ត្រូវនឹកដល់និស្ស័យចិត្តថ្ងៃមរបស់យើងជាមុនសិន" ។

សូម្បីដូច្នោះ អ្នកនិពន្ធគង់អាស្រ័យគម្ពីរជាប្រធាន ហើយអាងដល់គម្ពីរជាដរាប ប្រហែលជាក្រោយដែលបានពិសោធឲ្យឃើញដោយខ្លួនលោកជាមុន ចំណែកសេចក្ដីក្នុងគម្ពីរណាដែលលោកពិសោធ មិនឃើញច្បាស់ លោកទុកមួយអន្លើ ឬក៏បដិសេធថាមិនពិតក៏មាន ។

ត្រង់នេះខ្ញុំយល់ថា បញ្ញាបុថុជ្ជនមិនអាចថែងច្បាស់នូវប្រស្នាដែលនៅក្នុងភូមិនៃបញ្ញាលោកុត្តរបានឡើយ ចំណែកនរកសួគ៌ក៏ដូចគ្នាដែរ មំសចក្ខុមិនអាចមើលឃើញច្បាស់ប្រាកដដូចបញ្ញាចក្ខុឡើយ ដូច្នេះនឹងទុកគន្ថរចនាចារ្យជាអ្នកសរសេររឿងបញ្ឆោតលេង ដោយឥតគោលចារិក ក៏ពិបាកនឹងហ៊ានទទួលព្រមផង វៀរលែងតែមានហេតុផលសំខាន់ៗយកមកអាង ។

តែសូមល្បងពិចារណាតាមគោលការណ៍អ្នកនិពន្ធ ល្បងបន្តិចមើល ។

ការសម្លាប់សត្វចាត់ទុកជាបាប ជាផ្លូវទៅនរកក្នុងពុទ្ធសាសនា ។ បើគិតតាមចិត្តថ្មីរបស់អ្នកបាញ់ ពេលយល់ម្រឹគជាអារម្មណ៍គាប់ចិត្ត មានចិត្តត្រេកអរណាស់លុះបាញ់ម្រឹគបាន យកសាច់មកបរិភោគក៏សប្បាយមិនតិចឡើយ ចិត្តខណៈនោះពុំមែនចិត្តជាទុក្ខទេ ក៏គួររាប់ចិត្តបាណាតិបាតទុកជាចិត្តសួគ៌បាន ។

បណ្ដាបាបទាំងឡាយ ច្រើនតែទាស់ចិត្តអ្នកប្រព្រឹត្តឲ្យសប្បាយក្ដើតក្ដើនជាដរាប ទើបលង់ប្រព្រឹត្តញាប់មិនចេះអស់មិនចេះហើយ បើគ្មានស្នេហ៍ដូច្នេះទេ មុខជាគ្មាននរណាត្រូវការទេ សូម្បីយល់កង់ចក្រជាផ្កាឈូក ក៏គង់នាំចិត្តឲ្យរីករាយសប្បាយ តើសន្ដានចិត្តបែបនោះជាសន្ដានចិត្តសួគ៌ឬ ។

ចំណែកអ្នកប្រព្រឹត្តល្អតាមច្បាប់ព្រះពុទ្ធសាសនាវិញ មានការប្រព្រឹត្តឲ្យខុសពីប្រក្រតីធម្មតានៃសាមញ្ញជនឥតសប្បាយទៅកើតទេ នឹងឲ្យឈ្មោះថា កំពុងស្ថិតក្នុងស្ថានសួគ៌ពុំបាន តាមន័យរបស់លោកសួន–សារិន្ទ នឹងថាកំពុងចុះនរកបានឬទេ ?

បើនឹងជូនឧទាហរណ៍សំរាប់សំអាងរឿងនេះផងក៏បាន ដូចភិក្ខុសាមណេរចំរើនភេទជាបព្វជិត ខំប្រព្រឹត្តតាមក្រិត្យវិន័យ ឥតមានពេលនឹងរីករាយសប្បាយដូចឃរាវាសទេ មានតែពេលច្បាំងតតាំងនឹងកិលេសឥតល្ហែ គឺជាពុំបានសោយរបស់សួគ៌ទេ ឯការឈ្នះបានត្រឹមសេចក្ដីស្ងប់ដែលពុំមែនជាកេតនភណ្ឌនៃស្ថានសួគ៌ឡើយ ។ តើសេចក្ដីស្ងប់នេះជាពន្លឺនៃព្រះនិព្វានឬ?

បើគិតតាមយោបល់លោក សួន-សារិន្ទ ព្រះនិព្វានតោងតែស្ថិតក្នុងចិត្តមនុស្សដូចស្ថាននរកនិងស្ថានសួគ៌ដែរ ទើបគេអាចពិសោធបាន បើពុំដូច្នេះទេតោងទុកមួយអន្លើ ឬក៏មិនជឿក៏បាន ។ នឹងថាដូច្នេះទៅកើតទេ? ។

មួយវិញទៀត លោក សួន សារិន្ទ ចូលចិត្តថា ភ្លើងនរក គឺភ្លើងរាគៈ ទោសៈ មោហៈ នោះឯង ។ ធម្មតាមនុស្សរមែងប្រកបដោយអកុសលមូលទាំង ៣ មិនដែលដាច់ឡើយ ដូច្នេះភ្លើងនរកឆេះដរាបក្នុងខ្លួនមនុស្ស ក៏មនុស្សលោកពិតជាស្ថាននរកតែម្ដង ។ ណារាងកាយរបស់មនុស្សជាសំបុកនៃទុក្ខ ជាតិក៏ជាទុក្ខទៅហើយដូច្នេះ តើសួគ៌មានឱកាសឯណានឹងចូលមកសណ្ឋិតក្នុងចិត្តបាន តាមយោបល់លោក សួន-សារិន្ទ?

បញ្ហានរក–សួគ៌ ដាច់នឹងប្រស្នាស្លាប់ហើយកើតទៀតឬទេ បើតាមសេចក្ដីពន្យល់របស់អ្នកនិពន្ធរឿងហាក់ដូចជាមិនកើតទៀត ព្រោះទទួលផលកម្មរួចទៅហើយ បើកើតទៀតក៏កើតជាមនុស្សដដែល ទិដ្ឋិបែបនេះត្រូវឬខុស ?

ចំណែកសត្វតិរច្ឆានដែលច្រើនពាសពេញក្នុងលោក នឹងអាចកែនិស្ស័យរបស់វាបាន ចាប់កំណើតជាមនុស្សបានឬទេ? បើបានដែរ សេចក្ដីល្អរបស់

លោកស្ទួន–សារិទ្ធ ចំពោះការចំរើនចំនួនមនុស្សក៏នឹងអស់ទៅឯង ។

ខ្ញុំពុំបានដាច់ចិត្តគាន់វាទៈបែបណាទេ សេចក្ដីខាងលើនេះជាសេចក្ដីបញ្ជាក់ដើម្បីបំបាត់ការសង្ស័យរបស់ខ្ញុំប៉ុណ្ណោះ ។ សូមលោកបណ្ណាធិការជម្រះឲ្យស្រឡះឲ្យខាន ។

សូមទទួលសេចក្ដីរាប់អានដ៏ស្មោះអំពីខ្ញុំ ។

អ្នកអានម្នាក់

x x

x

## បញ្ហាក្នុងការប្រតិបត្តិធម៌
## នៃអ្នកស្រុកស្ទឹងត្រង់

ក្នុងឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម មានកើតចលាចលដោយធម៌អាថ៌ជាច្រើន តែសូមលើកយកតែចលាចលមួយដែលកើតមានរាល់ឆ្នាំ ហើយស្ទើរតែទាស់ទែងគ្នាទៅវិញទៅមក មកបរិយាយ ដើម្បីអំពាវនាវរកអ្នកប្រាជ្ញឲ្យ ជួយដោះស្រាយ?

អ្នកស្រុកជាពុទ្ធបរិស័ទ ស្រុកស្ទឹងត្រង់ទាំងអស់ត្រូវសន្មតជាពីរពួក គឺពួក "ក" នឹងពួក "ខ" "ក" យល់ថាអវសេសភត្ត គឺភត្តជាសំណល់អំពីភិក្ខុសាមណេរឆាន់ហើយ ឧបាសក-ឧបាសិកា នាំគ្នាបរិភោគអាហារសំណល់នេះបាន ឥតមានទោសពៃរ៍អ្វីទេ គឺជាបរិភោគបានតាមសេចក្ដីត្រូវការ " ខ " យល់ថាបរិភោគប្រើប្រាស់មិនបាន មានទោសធំណាស់ ត្រូវធ្លាក់ទៅលន្ធូវគត្ត ដែលនៅសល់ក្នុងចានទាំងប៉ុន្មាន ហើយផ្ទុសជាថ្មីមកបរិភោគវិញ ព្រោះមានដល់គម្ពីរពុទ្ធសាសនាជាច្រើន, ក្នុងគម្ពីរនោះមានចែងថា "គ្រហស្ថមិនត្រូវបរិភោគអាហារសំណល់របស់បព្វជិតទេ លុះតែបានថ្វាយខ្លួនជាវេយ្យាវច្ចករ ទើបបរិភោគបាន, តែវេយ្យាវច្ចករនេះសោត បរិភោគបានតែក្នុងថ្ងៃដែលខ្លួនបានបម្រើបម្រាស់ភិក្ខុសាមណេរ បើថ្ងៃណាខានធ្វើកិច្ចវត្តនេះនឹងបរិភោគមិនបានឡើយ" ។ "ក" និយាយទៀងថាបើដូច្នោះ គ្រហស្ថមិនត្រូវចូលទៅក្នុងអារាម មិនត្រូវឡើងទៅលើកុដិ វិហារ សាលាផ្សេង ៗ ទេ ព្រោះសុទ្ធតែជាបច្ច័យរបស់បព្វជិតទាំងអស់ ' បិណ្ឌបាតប្បច្ច័យជាសំណល់ គ្រហស្ថមិនត្រូវបរិភោគ, ចីវរប្បច្ច័យ សេនាសនប្បច្ច័យ កុដិ សាលា វិហារ ជាដើម នឹងគិលានភេសជ្ជប្បច្ច័យក៏ដូចគ្នាដែរ ។

ដោយហេតុនេះ ពួក ( ក ) នឹង ( ខ ) មិនស្រុះយោបល់គ្នាដូច្នេះ នាំឲ្យអ្នកស្រុកស្ទឹងត្រង់ទាំងអស់ពិបាកធ្វើបុណ្យជាទីបំផុត, បើពួក(ក)ធ្វើបុណ្យទៅដិកបពួក (ខ) ឲ្យមករួមធ្វើបុណ្យផង ពួក (ខ) ថាយើងមិនចង់ទៅធ្វើបុណ្យជាមួយទេ ពួកនេះសុទ្ធតែចុះនរក ព្រោះស៊ីបាយសំណល់ពីលោកសង្ឃ, លុះពួក ( ខ ) ធ្វើបុណ្យទានណាមួយវិញ ទៅដិកបពួក ( ក ) ពួក ( ក ) និយាយថា យើងដូចជាមិនហ៊ានទៅរួមធ្វើបុណ្យជាមួយផងទេ ព្រោះយើងសុទ្ធតែជាអ្នកមិនបរិសុទ្ធ ជាពួកបាប មានបាបតាំងពីដូនជីតាមក ។

ពួក (ក) ច្រើនតែធ្វើបុណ្យចំពោះលោកក្នុងវត្ត

(លោកក្នុងស្រុក) ហើយជឿស្លាប់ទៅទេវលោកនៅក្នុងស្រុក, ពួក (ខ) ច្រើនតែជាអ្នកធ្វើបុណ្យចំពោះលោកផុតគ្គ (លោកក្នុងព្រៃ) ជឿស្លាប់ទៅទេវលោកនៅក្នុងព្រៃ ។

សេចក្ដីនេះអ្នកស្រុកស្ទឹងត្រែង សូមឲ្យគណៈកម្មការទស្សនាវដ្ដីមិត្តសាលាបាលី, ក្រុមជំនុំប្រែព្រះត្រៃបិដក និងលោកអ្នកប្រាជ្ញទាំងឡាយក្នុងប្រទេសកម្ពុជា មេត្តាជួយរិះរកពុទ្ធដីកា ឬ អដ្ឋកថាដែលមាននៅក្នុងគម្ពីរពុទ្ធសាសនា យកមកអធិប្បាយប្រាប់ពន្យល់យើងខ្ញុំផង បើឃើញថាបែបណាត្រូវជាង សមហេតុសមផលជាង យើងខ្ញុំនឹងអនុវត្តទៅតាមបែបដែលត្រូវនោះ, យើងខ្ញុំបានសង្កេតតាមគម្ពីរតូចៗ ដូចជា (ធម្មបទ) ជាដើម,តែមិនអស់សង្ស័យ ហេតុនេះ បើកាលៈទេសៈល្មមឆ្លើយបញ្ហានេះបាន សូមឆ្លើយឲ្យទាន់ យើងខ្ញុំចង់បានសេចក្ដីពិតនេះឆាប់ៗ ព្រោះកំពុងតែខ្វល់ក្នុងចិត្តខ្លាំងណាស់ ។

សេចក្ដីគួរពុំគួរសូមខន្តីអភ័យដល់យើងខ្ញុំ

អ្នកនិពន្ធ ភិក្ខុ ហុក សៀក សិស្សគ្រឹះស្ថានមធ្យមសិក្សាបាលី ក្រុងភ្នំពេញ ។

សូមសួរមិត្រអ្នកអានទាំងឡាយចំពោះបញ្ហានៃលិខិតសំនួរទាំងពីរនេះ បើមានយោបល់ក្នុងការដោះស្រាយបែបណា សូមដំណឹង ដើម្បីជាការពិសោធដល់បញ្ញាពុទ្ធជនកម្ពុជរដ្ឋ; ដល់លេខខាងចុង សឹមខ្ញុំនឹងជូនសេចក្ដីពិត ។ ហា. ហា.

## ដំណឹងព្រះពុទ្ធសាសនាសកលលោក

១- យើងបានដំណឹងពីទីក្រុងតូក្យូ (ប្រទេសជប៉ុន ថា មានសន្និសីទសាសនាអន្តរជាតិនឹងធ្វើនៅទីក្រុងតូក្យូវិហារហ៊ីគស្ស៊ីហុងគ័នជិ) Higashi Hongan-ji ពីថ្ងៃទី ១ ទៅ-ថ្ងៃទី៦សីហា ១៩៥៨ ។

ប្រទេសជប៉ុនបានចាត់ឲ្យអញ្ជើញនាយកគណៈពុទ្ធសាសនាខាងជើង-ត្បូង, នាយក្រុមប្រូតេស្តង់, នាយក្រុមកាតូលិក នាយក្រុមសមាមតិ, នាយក្រុមសាសនាហិណ្ឌូ, នាយក្រុមសាសនាមហាម័ត នាយក្រុមខាងធ្វើការសង្គម, នាយក្រុមខាងអ្នកនិពន្ធ នាយក្រុមខាងអ្នកអប់រំ ។ល។

សន្និសីទនេះមានវត្ថុបំណងដើម្បីនឹងរួបរួមសាសនានឹងលទ្ធិក្នុងសាកលលោករិះរកនូវមធ្យោបាយផ្សេងៗ ជាហេតុឲ្យមានសន្តិភាពលោកទៅអនាគត ។

## សេចក្ដីស្នើរបៀបវារៈ

ក- មធ្យោបាយដើម្បីនឹងបំផ្លាញនូវហេតុនៃការរឹករាំងនឹងវិបត្តិពិភពលោក ។ មធ្យោបាយនៃសហការសាសនាទាំងឡាយ ដើម្បីនឹងឲ្យបានសម្រេចទៅតាមវត្ថុបំណងនោះ ។

ខ) ការស្ថាបនានូវសន្តិភាពលោកជាអចិន្ត្រៃ ។ ធ្វើម្ដេចឲ្យពលភាពសាសនាទាំងឡាយរួបរួមគ្នាដោយម៉ឺងម៉ាត់ ដើម្បីនឹងទៅកាន់វត្ថុសន្តិភាពនោះ ។

គ) ការស្ថាបនានូវសុភមង្គលមនុស្សជាតិ ។ តើសាសនាទាំងឡាយរួបរួមគ្នាយ៉ាងណា ដើម្បី

សុខមង្គលមនុស្សជាតិនោះ ។

## តាមសេចក្តីស្នើពីសមាគមរៀបចំសន្និសីទ សាសនា

(Organiging committee of the Conference of World Religionists. M. yasabu shi monka, General secretary, Atago kaikan, 1-8 Shiba Atagocho Minato-ku, Tokyo, Japon)

២- បុណ្យវិសាខបូជានៅទីក្រុងប៉ារីសប្រទេសបារាំង, បានធ្វើនៅថ្ងៃសុក្រទី ៦ ឧសភា ពេលម៉ោង ២០,៣០ នាទី ឯយ៉ាលេខ ៦២ ស្ទួន, វិចឡូមុងដ៍ ដោយការឧបត្ថម្ភពីព្រះភិក្ខុវ៉ាប៉ាលនឹងព្រះភិក្ខុស្ហ៊ិន-កេលសៈ, ក្រោមអធិបតីភាពនៃឯកឧត្តម ថៃ-ប្រថ៊ប៉ាសែន, ឯកអគ្គរាជទូតថៃប្រចាំទីក្រុងប៉ារីសនឹងចំពោះមុខឯកឧត្តមការធារនៃប្រទេសភូមានាមស៊ុខ-ទិន ។

៣- បានដំណឹងពីទីក្រុងឡុងដ្រ៍ (ប្រទេសអង់គ្លេស) ថា:

ព្រះភិក្ខុម៉ីស្សគុនស៊ារ, ព្រះមហានយកត្ថេរ ព្រះភិក្ខុមហានាមត្ថេរៈបាននិមន្តទៅដល់ទីក្រុងឡុងដ្រ៍ ហើយលោកបានទៅសំណាក់នៅព្រះវិហារពុទ្ធសាសនា (London Buddhiot Vihara) ។ ។ លោកបានធ្វើបុណ្យវិសាខបូជានៅទីនោះជាឧឡារិក ។

៤- យើងទើបនឹងបានទទួលដំណឹងថាព្រះមហាថេរៈពុទ្ធ-វេតៈ-និយោធយ៉ាវ សយ ដាវ បានអនិច្ចធម្មនៅវត្តមួយដែលស្ថិតជិតគុហាស្ថាបនានូវឆដ្ឋសង្គាយនាព្រះពុទ្ធសាសនានាទីក្រុងរង្គូន ប្រទេសភូមា កាលពីថ្ងៃទី ៨ កុម្ភ ១៩៥៥ ក្នុងជន្មាយុ ៨០ ឆ្នាំ ។ ព្រះមហាថេរៈអង្គនេះលោកបានតែងសៀវភៅព្រះពុទ្ធសាសនា ១៣០ ក្បាលអំពីព្រះធម្ម ។ លោកអង្គនេះមានប្រាជ្ញាដ៏មុតមាំហើយជាបណ្ឌិតខាងពុទ្ធសាសនា បានជាកាលបុណ្យសម្ពោធលើកដំបូងនៃឆដ្ឋសង្គាយនានេះ គណៈប្រតិភូគ្រប់ប្រទេសបានបោះឆ្នោតយករូបលោកជាប្រធាន ។

សមាគមមិត្តសាលាបាលីសូមចូលកាន់មរណសញ្ញាចំពោះសពនេះដោយគារវភាពខ្ពង់ខ្ពស់ ។

---

## ពិធីហែព្រះសារីរិកធាតុ

ពីប្រទេសសិរីលង្កា siland មកក្រុងព្រៃនគរ saigon ពិធីនេះចាត់ជា ៥ផ្នែកដូចមានខាងក្រោមនេះគឺ

១- និយាយពីហេតុដើម

២- និយាយពីរបៀបតាំងតុសក្ការៈ

៣- និយាយពីពិធីហែព្រះសារីរិកធាតុ

៤- និយាយពីកោដ្ឋមាស-ប្រាក់

៥- និយាយពីកម្មវិធីបុណ្យ



## ១– ហេតុដើម

កាលពីរពេញឆ្នាំម្ភៃញីបញ្ចស័ក ព.ស. ២៤៨៦ / គ.ស. ១៩៤៣

នោះព្រះមហានាយកត្ថេរកោះលង្កា លោកបាននិមន្តព្រះសារីរិកធាតុមកដាក់តម្កល់ទុកនៅវត្តជេតពនព្រៃនគរ ជាដើម

កាលនោះក្រុមពុទ្ធបរិស័ទអ្នកជ្រះថ្លាជាច្រើននៅដែនកូសាំងស៊ីន មានលោកសឺង-ថាយ-ង្វៀនជាដំណាងបានស្នើសុំព្រះថេរៈអង្គនោះ ដើម្បីនិមន្តព្រះសារីរិកធាតុឲ្យយើងខ្ញុំបានមួយអង្គផង ។

ពីត្រឹមឆ្នាំនោះរហូតមកទើបសម្រេចជាបានព្រះសារីរិកធាតុក្នុងថ្ងៃអង្គារ ២ កេីត ខែចេត្រ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ (១៩ មេសា ១៩៥៤នេះ) ។

## ២. របៀបតាំងតុសក្ការៈ

ពិធីរៀបចំតាំងតុសក្ការៈនេះ មុខគួរឲ្យស្តាយណាស់ ព្រោះវត្តចន្ទរង្សីមានទីចង្អៀតពេកមិនល្មមនឹងការគាក់តែង សូម្បីយ៉ាងនោះក៏ដោយក៏គង់លោកសឺង-ថាយ-ង្វៀន អាចចាត់ការល្មមគួរជាទីជ្រះថ្លាបានតាមបន្ទាល់ដូចបានដកស្រង់គោលៗខ្លះ មករៀបរៀងក្នុងទីនេះ ៖

មុនដំបូងលោកដំណាង មានលិខិតប្រគេន-ជូនដំណឹងទៅខេត្រនានានៅដែនកូស័ងស៊ីនអំពីរឿងបុណ្យនៅថ្ងៃអង្គារ ១២ កេីត ខែចេត្រ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃ ១៩ មេសា ឆ្នាំ ១៩៥៤នេះ ។

| | |
|---|---|
| ហត្ថលេខា | ហត្ថលេខា |
| ដំណាងខ្មែរកម្ពុជាក្រោម | លោកចៅអធិការ |
| ប្រធានគណកម្មាធិការនាយក | វត្តចន្ទរង្សីព្រៃនគរ |
| ប្រចាំក្រុងព្រៃនគរ | ឡឹម-ឯម |
| សឺង - ថាយ - ង្វៀន | |

លុះដល់កំណត់ថ្ងៃដូចខាងលើនេះហើយ ទើបគណកម្មាធិការនាយកចាត់វិធានការដូចមានតទៅនេះគឺៈ

## (ក) រូបខេត្រព្រែកឬស្សី

ខេត្រនេះ មានតាំងតុសក្ការៈ ១ នៅខាងទិសនិរតីវត្ត ឈមមុខមកខាងកើត ចារឹកអក្សរធំៗលើផ្ទាំងសំពត់ពណ៌លឿង ជាសញ្ញាឈ្មោះខេត្រនិងថែមពាក្យថា ជយោ! ព្រះសារីរិកធាតុ ឯខាងក្នុងសាលសង់ពាសពិតានសំពត់ពីខាងលើ ចងស្លឹកឈើផ្កាឈើស្រស់ទៀតស្រឡាត់ រំលេចគ្រឿងអគ្គិសនីពណ៌ក្រហមលឿង-ស បៃតង ភ្លឺព្រោងព្រាតដូចពន្លឺផ្កាយបញ្ចេញរស្មីតាមស្រទាប់ពពក ។

សសរទាំងឡាយគ្រប់ល្វែង សង់ស្រោបស្លឹកឈើស្រស់ ហើយបន្ទំពណ៌ផ្កាក្រដាសក្លាទ្រាលមុខ គួរឲ្យចង់ក្រឡេកមើលមិនដាក់ភ្នែក ហើយតែងចងទង់ជាតិទង់សាសនាតាមលំដាប់ជួរសសរពីខាងមុខ គួរជាទីគោរព, ផ្ទៃសាលខាងក្រោម គេរៀបតុ-កៅអីសម័យគ្រប់ល្វែង សម្រាប់ទទួលបណ្ដាជនដែលមកធ្វើសក្ការៈព្រះសារីរិកធាតុនិងសម្រាប់ព្រះសង្ឃគង់ក្រសាល ។

ត្រង់តុតាំងសក្ការៈសង់រចនាចាក់ចេក ភាពបុស្ស-បុកមានសសរជា ៤ សណ្ឋាន មានកំពូលស្រួច ហើយតាំងស្តូបតែរបស់មានដំឡៃប្លែកៗផ្សេងៗ ទោះជារបស់ទំនើបក្តី របស់បុរាណក្តី មានតាំងបានតែងរូបចម្លាក់ជាដើម ជារបស់ចុះសម័យ ។ល។

លោកអ្នកចាត់ការដំណើរការខេត្រនេះ ប៉ែកខាងព្រះសង្ឃឃើញមានលោកគ្រូ-ថ្នាក់ ចៅអធិការវត្តពោធិសិរី លោកគ្រូ-មៀច ចៅអធិការវត្តកំពង់ស្ពាន, លោកមហាឧត្តមវិជ្ជាថាច់-ប្រាជ្ញ; ប៉ែកខាងគ្រហស្ថមានលោកថាច់-លី (ពលបាលត្រី) ក្នុងរាជការយៀកណាម និងគណកម្មការខេត្រ មានអ្នកអាចារ្យ-កង់ជាដើមជា-មួយនឹងក្រុមពុទ្ធបរិស័ទទាំងឡាយ ។

## (ខ) រូបខេត្រក្រមួនស

ខេត្រនេះ មានតាំងតុសក្ការៈ ១ នៅទិសបស្ចិមឦសាន ខាងក្រោមសាលាជំនុំរបស់វត្ត ការរៀបចំស្រដៀងគ្នា មានសរសេរអក្សរធំៗលើផ្ទាំងសំពត់ជាសញ្ញា ដូចខេត្រឯទៀតដែរ, លោកអ្នកចាត់ការដំណើរការខេត្រនេះ ប៉ែកខាងព្រះសង្ឃឃើញមានព្រះតេជ-គុណមេគណ ខេត្រក្រមួនសនិងគណកម្មការរបស់លោកទាំងព្រះសង្ឃទាំងគ្រហស្ថជាច្រើន ។ល។

## (គ) រូបខេត្រព្រះត្រពាំង

ខេត្រនេះ មានតាំងតុសក្ការៈ ១ ក្នុងសាលាជំនុំរបស់វត្ត នៅទិសនិរតីនៃព្រះវិហារ មានសរសេរអក្សរធំៗលើផ្ទាំងសំពត់ជាសញ្ញាសម្រាប់ខេត្រនោះ ។ លោកអ្នកចាត់ការដំណើរការខេត្រ ប៉ែកខាងព្រះសង្ឃឃើញមានព្រះតេជ-គុណ អនុគណវត្តចេកជ្រុំជាប្រធាននិងសហការីរបស់លោកគឺៈ លោកមហាថាច់-ផាត់ វត្តពិសី, លោកគ្រូសុត្ត ស៊ុផាន់, លោកគ្រូសុត្តបាសវត្តពោធិ-សាលរាជ ប៉ែកខាងគ្រហស្ថឃើញមានអ្នកអាចារ្យចៀង សម្រាប់វត្តពិសី និងគណកម្មការសម្រាប់ខេត្រនោះ ។ល។

## (ឃ) រូបខេត្តពលលាវ

ខេត្តនេះ មានតាំងតុសក្ការៈ១នៅទិសបស្ចិមនៃព្រះវិហារ មានគណកម្មការខេត្តទាំងព្រះសង្ឃទាំងគ្រហស្ថជាច្រើននាក់ចាត់ចែងបុណ្យ មានសរសេរអក្សរធំៗលើផ្ទាំងសំពត់ ជាសញ្ញាសម្រាប់ខេត្តដូចទីឯទៀតដែរ ។

## (ង) រូបខេត្តឃ្លាំង

ខេត្តនេះមានតាំងតុសក្ការៈ១នៅទិសឧត្តរនៃព្រះវិហារ មានសរសេរអក្សរធំៗជាសញ្ញាសម្រាប់ខេត្តដែរ លោកអ្នកចាត់ការដំណាងខេត្ត មានព្រះតេជ-គុណព្រះនាម-អ៊ុម ចៅអធិការវត្តពោធិ៍ជាអ្នកបញ្ជាការជាមួយនឹងគណកម្មការខេត្តនោះ ។ល។

## (ច) ទីក្រុងព្រៃនគរ

មានពុទ្ធបរិស័ទជាតិកម្ពុជានឹងយៀកណាម មកពីចំណុះវត្តទាំង៣គឺៈ វត្តចន្ទរង្សី ១, វត្តពោធិរង្សី ១, វត្តដេតពន ១, រួមគ្នាតាំងតុសក្ការៈជាមួយគ្នា នៅទិសទក្សិណនៃព្រះវិហារ ។ មានមន្ទីរឃោសនាការ១ទៀតនៅល្វែងជាន់ក្រោមត្រង់កុដិចាក់បេតុងល្អស្អាតនៅខាងត្បូងព្រះវិហារដែរ មន្ទីរនេះមានចារឹកអក្សរធំៗថា ទីនេះសម្រាប់ទទួលសក្ការៈបូជាចំពោះព្រះសារីរិកធាតុ ទាំងមានការផ្សាយរឿងផ្សេងៗគឺ- ចែកសៀវភៅ ពតមានឯទៀតតាមសំឡេងឧគ្ឃោសនស័ព្ទ ។ មានគណកម្មការទីក្រុងព្រៃនគរ ដែលមានលោក សឺង-ថាយង៉ៀងជាប្រមុខ អ្នកចាត់ចែងការ ។ល។

ឯខាងក្នុងព្រះវិហារថ្មី មានតាំងតុសក្ការៈសម្រាប់ដំកល់ព្រះសារីរិកធាតុ ពីខាងមុខបល្ល័ង្ក ដែលមានទូឈើវិសេសពីអែមសងខាង សម្រាប់ទទួលហិរញ្ញវត្ថុជាពុទ្ធបូជា មានក្រាលអាសនៈគឺកន្ទេលព្រំល្អៗពេញទាំងព្រះវិហារសម្រាប់ព្រះសង្ឃគង់ ។

x x

x

# ៣ ពិធីហែព្រះសារីរិកធាតុ

ពីកាលចំណតអាកាសយានឆ្ពោះវត្តចន្ទរង្សីព្រៃនគរ វេលាម៉ោង ១៣ ថ្ងៃសៅរ៍ ២ កើតខែពិសាខ ឆ្នាំមមែសប្ត-ស័ក ព.ស. ២៤៩៨ (២៣ មេសា ឆ្នាំ ១៩៥៥) ព្រះនាវទេត្ត្រ នាំព្រះសារីរិកធាតុ ឆ្ពោះមកពីសិង្ហបុរីសំដៅព្រៃនគរ, វេលានោះពួកព្រះសង្ឃប៉ែកខាងភ្នំពេញមានព្រះវិន័យសង្វរាជ-គង់ សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ព្រះគ្រូវ៉ាង វត្តសារ៉ាវ័ន ព្រះគ្រូថាញ់ចៅអធិការវត្តតេនាពម ព្រះមេគណ អនុគណ ចៅអធិការឧបជ្ឈាយ៍ ដែលនិមន្តមកអំពីនានាខេត្តនៅកម្ពុជាក្រោមនឹងព្រះសង្ឃចិន-យួន ព្រមទាំងពុទ្ធបរិស័ទបព្វជិត



គ្រហស្ថគ្រប់ភាសា ទាំងប្រុសទាំងស្រីរាប់សែននាក់ (១០០.០០០) ដែលមានគណប្រតិភូខ្មែរនិងគណកម្មការព្រៃនគរ ជាអ្នកត្រួតត្រានាំគ្នាទៅចាំនៅចំណតអាកាសយាន ។

លុះអាកាសយានចុះចតឈប់ស្រួលបួលហើយ ព្រះសង្ឃ ៨-១០ អង្គចូលទៅទទួលព្រះសារីរិកធាតុនាំហែចេញមក ព្រះសង្ឃច្រើនអង្គឈរតម្រៀបជាពីរជួរអមសងខាងផ្លូវ តាំងពីអាកាសយានដរាបដល់រថយន្តដែលមានគ្រឿងតាំងភាពបុស្សបុក សម្រាប់ដឹកលំហែ មានពុកអាចារ្យពីររូបស្លៀកពាក់សកាន់ក្លស់បាំងថ្វាយ ។

## ឯក្បួនហែដូចមានខាងក្រោមនេះ

(ក) ទោចក្រយានយន្ត (ម៉ូតូស៊ិក) ៣ គូជិះបរសន្ទឹមៗ យោងមុខ ។

(ខ) រថយន្តតូចៗពីរបីសម្រាប់គណៈប្រតិភូនិងគណកម្មការអ្នកចាត់ក្បួន ។

(គ) រថយន្តតាំងបុស្សបុកដឹកលំព្រះសារីរិកធាតុ មានអាចារ្យអ្នកបាំងក្លស់ថ្វាយ ។

(ឃ) អ្នកកាន់ផ្ទាំងសំពត់ចារឹកអក្សរសម្រាប់ក្រុមនីមួយៗដែលបានមកហែជាបន្ទោះៗ ។

(ង) អ្នកកាន់ទង់សាសនាដើរអមទាំងសងខាង តាមលំដាប់លំដោយគ្នា ក្រុមព្រះសង្ឃស្មូត្រនមស្សការ និមន្តជាប់ជាមួយនឹងរថបុស្សបុក, ក្រុមគ្រហស្ថដើរតម្រៀបជាជួរៗហែតាមក្រោយ អ្នកខ្លះកាន់ផ្កាភ្ញី អ្នកខ្លះកាន់ទៀនធូបមានបណ្ដាយប្រវែង ៥ គីឡូម៉ែត្រ រថយន្តតូច-ធំជាច្រើនបើកតាមក្រោយ មនុស្សអ្នកឈរមើលក៏ឈរតម្រៀបត្រៀបត្រាគ្រប់ថ្នល់ គ្រប់ច្រកល្ហក ទាំងស៊ីវិល ទាហាននិងមន្ត្រីក្រសួងជាតិយៀកណាម នៅក្រុងព្រៃនគរនោះ ។

ចម្ងាយពីចំណតអាកាសយានមក ស៊ុំរសរយៈ

វេលា ៥ ម៉ោង គឺពីម៉ោង ១៣ ដល់ម៉ោង ១៨ ទើបបាន ដល់វត្តបទុមវត្តី ។

## ៤ កោដ្ឋដំកល់ព្រះសារីរិកធាតុ

កោដ្ឋនេះ មានពីរប្រភេទគឺ កោដ្ឋប្រាក់ពីខាងក្រៅ ១ ស្តូបមាសនៅខាងក្នុង ១

(ក) កោដ្ឋប្រាក់មានទំហំ ០ម៥០ បួនជ្រុង មាន កំពស់ពីត្រឹមជើងកោសឡើងដល់ក្បាំង ០ម៥០ មាន កំពូលពីត្រឹមក្បាំងឡើង ០ម៥០ រួមកំពស់ ១ ម៉ែត្រគត់, មានកញ្ចក់ទាំង ៤ ជ្រុង សណ្ឋានដូចទូធម្មតា រួមទម្ងន់ ប្រាក់ចំនួន ១៨ គីឡូ ៦០ ប្រាក់ទាំងនេះបានមកអំពី សព្វាលង្ការទាំងពួងដែលចាស់គ្រាំគ្រាបាក់បែកខ្លះ

(ខ) ស្តូបមាសរាងមូលទំហំ ០ម,២០ រាស់ត្រង់ កណ្តាល មានកំពស់បល្ល័ង្ក ០ម,១០ និងទំហំបល្ល័ង្ក ០ម,១០ គំរបកំពូលទំហំ ០ម,១០ មានកែវចរណៃមូល ភ្ជាប់ជាមួយនឹងកំពូល រួមកំពស់ស្តូបប្រមាណ ០ម,៤៥ មានជើងពានមាសស្ទួចតូច១តភ្ជាប់នឹងបល្ល័ង្ក សម្រាប់ ដំកល់ព្រះសារីរិកធាតុខាងក្នុងកោដ្ឋប្រាក់នោះ រួមទម្ងន់ មានចំនួន ៦៤០ក,៣៣ ។ មាសទាំងនេះបានមកអំពី សព្វាលង្ការទាំងពួងដែលចាស់គ្រាំគ្រាបាក់បែកខ្លះ ។

កោដ្ឋនេះជាស្នាដៃជាង ដែលល្បីឈ្មោះនៅក្រុង ភ្នំពេញគឺ លោកជា.ប៊ុន១ ទីប្រឹក្សាវាំង ក្រសួងព្រឹទ្ធ សភា អ្នកចាត់ចែងការទាំងបានជួយប្រាក់ជាច្រើនក្នុង ការកសាងកោដ្ឋនេះ ។ លោកទៀង-នៅ១ ទីឧកញ៉ា ចំណានប្រើជាគ្រូបនាដើមវិទ្យុផុតលេខ អ្នកតាក់តែង ក្បូរក្បាច់ ហើយចាត់ការធ្វើរហូតដល់បានសម្រេច ។

ឯអ្នកម្ចាស់កោដ្ឋគឺ ក្រុមពុទ្ធបរិស័ទ បព្វជិត គ្រហស្ថក្នុងខេត្តទាំងឡាយនៅកម្ពុជាក្រោម មាន លោកសឺង-ថាយ-ធៀងជាអ្នកផ្តើម ។ លុះដល់ម៉ោង១៦ ថ្ងៃសុក្រ ១កើតខែទាំងដែល ទើបព្រះញាណកោសល ញាណ-ឈឹម ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសន បណ្ឌិត្យ លោកលុយ-ហុង មេហាងកុមារពេទ្យនៅ ផ្សារដំបូកភ្នំពេញ លោកថាច់-ញាណអតីតចៅហ្វាយ- ស្រុកកិត្តិយសបំរើរបស់លោកសឺង-ថាយ-ធៀង ទៅ ទទួលយកកោដ្ឋអំពីលោកជា-ប៊ុន បំរុងនឹងនាំយកទៅ ឯព្រៃនគរ ។ ដល់ព្រឹកឡើងម៉ោង ១០ និង ៣០, ថ្ងៃសៅរ៍ខែទាំងដែល ទើបព្រះញាណកោសល, កុមារពេទ្យ ព្រះមហាប៉ាង-ខាត់វត្តឧណ្ណាលោមបា នាំ កោដ្ឋនោះឆ្ពោះឋានទៅព្រៃនគរ ។ ម៉ោង ១៨ និង ៣០ បាននិមន្តនឹងអញ្ជើញទៅដល់វត្តបទុមវត្តី បន្ទាប់វេលា ដែលគេហែព្រះសារីរិកធាតុមកដល់វត្តនេះដែរ បណ្ដា ក្រុមពុទ្ធបរិស័ទទាំងម៉ឺន-សែនពាន់នាក់រង់ចាំនឹងមើលផ្លូវ លុះដឹងថាកោដ្ឋមកដល់ហើយ ក៏មានសេចក្តីសោមនស្ស រីករាយឥតឧបមាបានឡើយ អ្នកខ្លះទះដៃស្រែកហ៊ោ អ្នកខ្លះទទួលសាធុ! អ្នកខ្លះស្រែកជយោ! ប្រគេនសព្ទ សាធុការពរអំណរគុណចំពោះលោកទាំង ៣ រូប មាននាមដូច ខាងលើរួចហើយ នាំឡើងទៅកាន់ព្រះវិហារដំកល់ ព្រះសារីរិកធាតុក្នុងគ្រានោះឯង ។

# ៥ និយាយពីកម្មវិធីបុណ្យ

ទី ១- នៅថ្ងៃ ៦ ᧡ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២២ មេសា ១៩៥៥) លោក សឺង-ថាយ-ឆៀង ឲ្យប្រជុំពុទ្ធបរិស័ទនៅវត្តចន្ទរង្សី ព្រៃនគរ (ផែកភាគត្បូង) ។

ទី ២- នៅថ្ងៃ ៧ ᧢ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៣-៤-៥៥) ។

ម៉ោង ១៣ ទទួលព្រះសារីរិកធាតុនៅទីធ្លាចំណតអាកាសយានព្រៃនគរ ។

ម៉ោង ១៨ ហែព្រះសារីរិកធាតុទក្សិណាព្រះវិហារចន្ទរង្សី ។

ម៉ោង ១៨,៣០ អញ្ជើញគោដ្ឋឡើងកាន់ព្រះវិហារ ដំកល់ព្រះសារីរិកធាតុ បន្ទាប់មកព្រះនារទថេរ លោករៀបរាប់ប្រវត្តិពីដំណើរមកកាន់ទីក្រុងព្រៃនគរ ។

ម៉ោង ១៩ បើកឱកាសឲ្យពុទ្ធបរិស័ទចូលធ្វើការ-កិច្ចចំពោះព្រះសារីរិកធាតុ ។

ម៉ោង ២០,៣០ គណកម្មការនិមន្តព្រះនារទថេរ សំដែងធម៌ទេសនាជាភាសាអង់គ្លេស, ព្រះមហាប៉ាង ខាត់ ក្រុមជំនុំព្រះត្រៃបិដកប្រែជាភាសាខ្មែរ តិក្កុ គូ-ឆៀង ប្រែជាភាសាវៀតណាម ដល់ម៉ោង ២៤ អធ្រាត្រទើបចប់ ។

បន្ទាប់មកពួកអ្នកភ្លេងប្រគំតូរ្យតន្ត្រីល្បែងកំរង់ ល្បែងផ្សេងៗច្រើនប្រភេទរហូតដល់ភ្លឺ ។

ទី ៣ នៅថ្ងៃ១ ᧣ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៤-៤-៥៥) ។

ម៉ោង ៨ ប្រជុំពុទ្ធបរិស័ទដង្ហែព្រះសារីរិកធាតុមួយអង្គទៀតពីវត្តចន្ទរង្សីទៅកាន់វត្តព្រះសង្ឃចិន ប៉ែកខាងមហា-យាន នៅផ្សារធំ (ចឺឡឹង) (Chô Lôn) ព្រៃនគរ ។

ម៉ោង ១៣,១៤ ពុទ្ធបរិស័ទចូលធ្វើការកិច្ចទៀត ។

ម៉ោង ១៦ គណកម្មការនិមន្តលោកព្រះគ្រូ ថាញ់ ចៅអធិការវត្តរតនារាមភ្នំពេញ សំដែងធម៌ទេសនាជាភាសាវៀតណាម ប្រែចេញជាភាសាកម្ពុជា, ដល់ម៉ោង ១៨ ទើបចប់ ។

ម៉ោង ១៩ ប្រគេនភេសជ្ជៈព្រះសង្ឃតាមលំដាប់សាលបុណ្យ ។

ម៉ោង២០,៣០គណកម្មការនិមន្តព្រះញាណកោ-សលញាណ-ឈឹន សំដែងធម៌ទេសនាអំពីប្រវត្តិព្រះសារីរិកធាតុនិងព្រះធាតុខ្ចាតធំ-តូចរបស់ព្រះគោតមបរមគ្រូជាអម្ចាស់នៃយើង វេលា ៤០ នាទីទើបចប់ធម៌ទេសនា ។

ម៉ោង ២១,៣០ ព្រះមហាប៉ាង-ខាត់ សំដែងធម៌ទេសនាតទៅទៀត អំពីពុទ្ធគុណនិងចរិយារបស់ព្រះអង្គរហូតដល់យប់ជ្រៅ ។

បន្ទាប់ពីនោះពួកអ្នកល្បែងគ្រប់ប្រភេទលេងមហោស្រពជាដើម រហូតដល់ភ្លឺដូចយប់មុនៗ ។

ទី ៤- នៅថ្ងៃ ២ ᧤ ៦ ឆ្នាំមមែសប្តស័ក

ព.ស. ២៤៩៨ (២៥-៤-៥៥) ។

ម៉ោង ១០, ៣០ ព្រះញាណកោសល, ព្រះមហាប៉ាង-ខាត់, ព្រះគ្រូចាញ់ ចៅអធិការវត្តរតនារាម, និងកុមារពេទ្យ លួយ ហុង វិលត្រឡប់ទៅភ្នំពេញវិញ ។ វេលាយប់នោះព្រះវិន័យសង្វរ ពជ-គឹង, ព្រះគ្រូប៉ាង នៅចាត់ការបុណ្យតទៅមួយយប់ទៀត ។ លុះដល់ថ្ងៃអង្គារ ៥ កើតខែពិសាខ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៦-៤-៥៥) ទើបធ្វើសម្រេចកិច្ច ។ រឿងហែព្រះសារីរិកធាតុនេះ នៅមានបញ្ហាស្មុគស្មាញចម្លែកជាសេចក្តីវិសេសជាងនេះច្រើនណាស់ ប៉ុន្តែអ្នកនិពន្ធដកស្រង់យកតែគោល ៗ មកចារឹកទុកក្នុងទីនេះជាសេចក្តីសង្ខេប ដើម្បីនឹងឲ្យកើតសទ្ធាជ្រះថ្លាត្រឹមប៉ុណ្ណេះ ។

មុននឹងបញ្ចប់ សូមសរសើរភ្នាក់ងារប្រតិភូស្ថានប្រទេសកម្ពុជា ប្រចាំនៅក្រុងព្រៃនគរដែលមានលោក ស៊ុំ-ហៀង អតីតសេនាបតីជាប្រមុខ និងលោកស៊ឹង ថាយ-ភៀង ដំណាងប្រជាជនខ្មែរកម្ពុជាក្រោម លោកទាំងនេះ អាចពុះពារចាត់ការបុណ្យរបៀបសាសនាក្នុងចំណោមប្រទេសវៀតណាម ឥតឲ្យមានវុទ្ធស្ថាន និងត្រួតត្រាពុទ្ធបរិស័ទរាប់សែន ឥតមានមោះមៃឡើយ ។

សូមថ្វាយសព្ទសាធុការពរចំពោះបរមក្សត្រប្រទេសកម្ពុជា និងរដ្ឋាភិបាលប្រទេសវៀតណាម សូមឲ្យបានគាំងនៅជាស្ថាពរអស់កាលដ៏លង់ ។ សូមឲ្យពុទ្ធបរិស័ទទាំងបព្វជិតគ្រហស្ថគ្រប់គាសានាចំណោមហែព្រះសារីរិកធាតុនេះជាដើម ឲ្យបានសម្រេចផលជាទីខ្ពស់គួរតាមប្រាថ្នាក្នុងឥធលោក បរលោក មានសម្បត្តិព្រះនិព្វានជាអវសាន ។

ធ្វើនៅថ្ងៃទី ១៣ ឧសភា ព.ស. ២៤៩៨ / គ.ស. ១៩៥៥

★ ★

★

សូមអភ័យទោស!

រឿងតាំងឡាយដែលធ្លាប់តែចុះប្រចាំក្នុងទស្សនាវដ្តីនេះ ដូចជារឿងប្រវត្តិក្មេងកំព្រាជាដើម ដែលទេះតែអាក់ខាននោះព្រោះអត្ថបទដែលគួរចុះជូនក្នុងពេលបន្ទាប់ៗនោះច្រើន ។

ខ្ញុំមានបំណងនឹងបោះបវត្តិក្មេងកំព្រាជូនមិត្តអ្នកអានឲ្យចប់តែម្តងដែរ ក្រែងលោមិត្តបានប្រទះ រឿងប្រលោមលោកដ៏ថ្លៃក្នុងផ្នៃនៃសាសនា បើមិត្តត្រូវការសុំផ្ញើនាមមកមុន ដើម្បីនឹងឆាយដល់ការវៃលលក ។

ហ.ហ.

# គណៈកម្មការទស្សនាវដ្ដី

## សូមជូនដំណឹង

សូមពិតទូល ជំរាប ព្រះតេជព្រះគុណ ព្រមទាំងមិត្តទាំងឡាយក្នុងការបត្តិអក្ខរាវិរុទ្ធនៃទស្សនាវដ្ដីលេខ ៣-៤ ៥.៦ នោះ គឺជាកំហុសនៃរោងពុម្ព ទោះបីអ្នកនៃបានពិនិត្យជួសជុលម្ដេចក៏ដោយ ក៏អ្នករោងពុម្ពមិនយកចិត្តទុកដាក់សោះ ការនេះយើងខ្ញុំបានប្រឹងប្រែងឲ្យម្ចាស់រោងពុម្ពសងតាមផ្លូវច្បាប់ដែរ តែថាយើងខ្ញុំបានពិភាក្សាតាមយោបល់ទៅឃើញថា ជាកិច្ចមួយដែលនាំឲ្យវែងឆ្ងាយ ក៏គណៈកម្មការយើងខ្ញុំបានដកសិទ្ធិនៃការបោះពុម្ពចេញពីរោងពុម្ពមុន ហើយចាប់តាំងពីលេខ ៧ នេះតទៅ សូមជ្រាបថា ជាសៀវភៅដែលបោះចេញពីរោងពុម្ពមួយថ្មីទៀត ហើយប្រសិនជា នៅរកកំហុសជាក់ខាន សូមមិត្តអភ័យទោសដល់យើងខ្ញុំ ហើយសូមទទួលនូវលេខតទៅដោយមេត្រីភាព ។

(គណៈកម្មការទស្សនាវដ្ដី) --

* * *

រឿងបញ្ចតន្ត្រៈរបស់ព្រះមហាប៉ាង-ខាត់នឹងបានចេញជាសៀវភៅនៅពេលខាងមុខនេះ ដោយលោកនិពន្ធបានជូនអំណោយដល់សមាគម ។

មានប្រលោមលោកមួយរឿងឈ្មោះឥន្ទ្រីយ៍ខ្មៅជាស្នាដៃលោកសួន-សារិទ្ធ ដែលជាគណៈកម្មការមួយរូបក្នុងទស្សនាវដ្ដីនេះ នឹងផ្សាយចេញក្នុងពេលឆាប់ៗ, ផ្ទៃរឿងមានអត្ថរសរឿងជាប្រលោមលោកសាមញ្ញ -

បន្តិចទៀតនឹងមានចេញទស្សនាវដ្ដីមួយទៀតហៅថា សង្គមថ្មី ផ្សាយអំពីលទ្ធិរបស់សង្គម -

មិត្តមានសទ្ធិចុះនាមជាប្រចាំខែ បើសិស្សគ្រូ-សូមៈផ្ញើនាមចំពោះលោកហួត-ហៀម អតិការរ៉ានការការ គ្រប់ពេញ តាំងសៀវភៅបញ្ចតន្ត្រៈ, ឥន្ទ្រីយ៍ខ្មៅ, ទស្សនាវដ្ដីសង្គមថ្មី ។

អរគុណទុកជាមុន

ម.ម.

# កំហុសរបស់ខ្ញុំ

ក្នុងជាន់ប្អូនទីគន្ធរួមមកហើយនេះ ខ្ញុំបានទទួលលិខិតរបស់មិត្តស្ទើរគ្រប់តំបន់ ដែលមានច្រើនសុទ្ធតែផ្ញើលិខិតបន្ទោសចំពោះកំហុសនៃសៀវភៅតាំងពីប្អូនលេខ គឺលេខ ៣-៤-៥-៦ ដែលខ្ញុំបានចេញផ្សាយរួចមកហើយ ពេលណាដែលខ្ញុំបានអានហើយខ្ញុំនឹកខ្មាសខ្លួន ខ្ញុំយ៉ាងក្រៃលែង, ព្រោះមានលិខិតខ្លះថាវត្ថុញាតិនឹកខ្មាសរហូតដល់សមាគមខ្លះទៀត នឹកឃើញដល់ដម្លៃអក្សរសាស្ត្រជាតិ, ខ្លះទៀតគេថាខ្ញុំចូលនិន្ទ្រាពេលកែអក្ខរាវិរុទ្ធ, ខ្លះទៀតគេថាខ្ញុំខ្ជិលមិនយកចិត្តទុកដាក់ ខ្លះទៀតគេថាខ្ញុំអន់ជាង ... ។ ខ្ញុំសូមជំរាបមិត្តថា ការស្តីបន្ទោសរបស់មិត្តទាំងឡាយ គឺជាអំពើមួយដ៏ប្រសើរក្រៃលែងរបស់មិត្តអ្នកអានគ្រប់ឋានៈ ខ្ញុំមិនមានគោលបំណងស្អប់ស៊ីសុំឲ្យបង្គិចបង្គួចទេឡើយ ខ្ញុំរឹតតែសប្បាយចិត្តជាខ្លាំងបំផុត បើសិនណាជាមិត្តចេះបន្ទោសខ្ញុំបានច្រើនបែបនេះ ។

ខ្ញុំមានសេចក្តីសង្ឃឹមជាពន្លឹកថា បើសិនណាជាមិត្តអាចបានមកជាអ្នកចាត់ការជាមួយនឹងក្រុមយើងខ្ញុំ ប្រហែលជាល្បឿននៃទស្សនាវដ្តីយើងមានដំណើរយ៉ាងប្រពៃជាងនេះទៅទៀត ព្រោះមិត្តសុទ្ធតែមានយោបល់ល្អខាន់សម័យសាសនិយម, តែជាការអកុសលពេក មិនបានឃើញរូប ឃើញតែលិខិតបន្ទោស ។

ចំពោះខ្ញុំសូមជំរាបមិត្តថា កំហុសទាំងឡាយនៃអក្ខរាវិរុទ្ធនេះ ខ្ញុំមិនបានដាក់ទៅលើជនរូបណាមួយទេ ខ្ញុំសូមទទួលដោយផ្ទាល់ខ្លួន; ហេតុដែលនាំឲ្យខ្ញុំទទួលនោះព្រោះថាពីមុនខ្ញុំបានស្រាវជ្រាវរករោងពុម្ពដែលបោះសៀវភៅយកថ្លៃថោកគួរសម ព្រោះថវិកានៃសមាគមយើងពុំសូវសម្បូណ៌, ការនេះក៏ធ្លាក់ទៅលើរោងពុម្ពជនបរទេស ហើយក៏បណ្តាលឲ្យកើតវិបត្តិហេតុដូច្នេះ នោះបើខ្ញុំប្រឹងបែបណាក៏ដោយ គឺអក្ខរាវិរុទ្ធនៅដដែល; ចាប់តាំងពីលេខ៧ តទៅខ្ញុំបានដកសិទ្ធិបោះ ចេញពីរោងពុម្ពយួនហើយ នឹងប្រគល់មកឲ្យរោងពុម្ពខ្មែរវិញ ទោះបីថ្លៃលើសពីរោងពុម្ពជនបរទេសក៏ដោយ, តាមការពិត. ដូចខ្ញុំជំរាបមកហើយនេះ សូមមិត្តអត់ឱនដោយសេចក្តីអនុគ្រោះពីលេខមុនៗមកផង ហើយសូមជួយគាំពារលេខតទៅទៀត ។

ក្រុមអនុណាជាមុខ

រោងពុម្ព អ៊ុក-អ៊ី-ហុល វិថីប៉ាស្ទ័របត្ត ភ្នំពេញ